



26.

កងវិរៈសេនាតូចនារីមួយ កងនៃភូមិភាគពិសេស រវាងឆ្នាំ១៩៧៤ ។ រូបនេះ បានថតដាក់ក្នុងក្រដាស ប្រាក់ដែលបានបោះពុម្ព នៅចិននៅចុងឆ្នាំនេះ។

## ជំពូក ៥

# កម្ពុជាប្រជាធិបតេយ្យ

ក្នុងបញ្ហាខ្មែរក្រហម ដូចដែលគេតែងតែនិយាយដូចបច្ចុប្បន្ននេះមានបញ្ហាច្រើនណាស់ ដែលធ្វើឲ្យខ្ញុំខ្វល់ខ្វាយក្នុងចិត្ត និងតប់ប្រមល់ទល់ប្រជោខ្លាំងណាស់។

ជាការពិតហើយ ប្រទេសយើង កម្ពុជាបច្ចុប្បន្ននេះ ត្រូវប្រឈមមុខនឹងមរតកមួយដ៏ធ្ងន់ធ្ងរនៃគំនុំគុំគួននឹងការភ័យខ្លាចដែលបដិវត្តន៍មួយ ដែលបានប្រែប្រួលដោយគ្មាននរណាបានប៉ាន់ស្មានមុនសោះ ទៅជាបដិវត្តន៍មួយដាច់ខាតជាងគេ ធ្វើឲ្យក្រឡាប់ចាក់ក្នុងសង្គមជ្រាលជ្រៅជាងគេ ដែលគេមិនធ្លាប់ឃើញមានសោះក្នុងសកលលោកពីមុនមក។

ប៉ុន្តែយើងគួរពិចារណាមើលផងដែរ តើបដិវត្តន៍មួយ ដូចជាបដិវត្តន៍របស់ពួកខ្មែរក្រហមនេះ ដែលបានកំចាត់កំចាយ ការលោភលន់របស់មហាអំណាចធំ មហាអំណាចមធ្យមបានម្តងទៅហើយនោះ តើវាអាចជាអំពើប្រព្រឹត្តរបស់មនុស្សម្នាក់ ឬមនុស្សមួយក្រុមតូចនោះបានទេ? ពិតជាមិនបានទេ។ មានមនុស្សច្រើនម៉ឺន ច្រើនសែននាក់ដែលបានដើរតាមបដិវត្តន៍នេះ ហើយដែលមិនញញើតនឹងបូជាជីវិតរបស់គេ ដើម្បីបុព្វហេតុបដិវត្តន៍នេះទេ។ ដូច្នេះប្រហែលជាមានអ្វីដែលគេខ្វះខាតយូរហើយ ដែលគេត្រូវការខ្លាំងណាស់ដើម្បីរស់។ ដូច្នេះបញ្ហាដែលចោទសួរ គឺតើហេតុអ្វីបានជាមានបដិវត្តន៍យ៉ាងនេះ? ហើយនៅចំពេលនេះ? តាមយោបល់ខ្ញុំ ចម្លើយចេញមកឯង។

បដិវត្តន៍នីមួយៗវាកើតចេញមក នៅពេលក្រោយមានសភាពការណ៍ប្រវត្តិសាស្ត្រមួយជាកំណត់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រវត្តិសាស្ត្រមួយជា






សម្តេចព្រះនរោត្តមសីហនុ ជាមួយ លោក ហ៊ុយនឹម, ខៀវ សំផន, ព្រះមហេសី (រាប់ពីខាងស្តាំមកនៅជួរមុខ) នៅស្ទឹងត្រែង មុនយាង ចូលទៅទស្សនៈកិច្ចក្នុងតំបន់រំដោះ។ ក្រោយមកលោកបើកឆ្នាំង សម្លនៅក្នុងដើងក្រានបាយយុវជនដើម្បីទតមើល។



សម្តេចនរោត្តមសីហនុ និង ព្រះមហេសី ម៉ូនិច ថតនៅឆ្នាំ ១៩៧៣
នៅមាត់ទ្វារមុខផ្ទះ លើភ្នំគូលេន ដែលព្រះអង្គដាក់នាមថា
"វិមានសរបស់យើងនៅតំបន់រំដោះ"



លោកសាឡុត សរ និង លោក នួន ជា នៅរតនៈគីរី ឆ្នាំ ១៩៦៩



21.

មហាសន្និបាទលើកទី៣នៃបក្សកុម្មុយនីស្តកម្ពុជា ប្រជុំក្នុងព្រៃ មិនឆ្ងាយប៉ុន្មានពីភ្នំដីនិត។ លោកសាឡុតសរ អង្គុយខាងមុខគេ នៅកណ្តាល។



18.

លោកឧត្តមសេនីយ៍ លន់ នល់ មេបញ្ជាការជាន់ខ្ពស់ពេលបង្ក្រាបការបះបោរកសិករនៅសំឡូត។



17.

កំណាត់ៗ វាបានបណ្តាលឲ្យមានការកាប់សម្លាប់ តែវាកើតចេញមកក្រោយពីមានការកាប់សម្លាប់ពីមុនមកៗ ឯការកាប់សម្លាប់ពីមុនមក យើងមើលតែនៅសំឡូតយើងយល់ហើយៗ

មតិជាទូទៅទាំងខ្មែរ ទាំងបរទេសយល់ថា "បើគ្មានសង្គ្រាមវៀតណាមទេ ប្រទេសកម្ពុជាប្រហែលជាអាចបន្តនៅដូចក្នុងអំឡុងទសវត្សរ៍ឆ្នាំ៦០យូរឆ្នាំតទៅមុខទៀតៗ ខ្មែរក្រហមនឹងស្ថិតនៅជាចលនាបះបោរមួយខ្វាំង ដែលរដ្ឋាភិបាលរបស់សម្តេចព្រះនរោត្តម សីហនុមិនអាចរំលាយបានទេ តែខ្មែរក្រហមក៏មិនមានកម្លាំងគ្រប់គ្រាន់ដើម្បីដណ្តើមយកអំណាចបានដែរៗ មតិខាងលើនេះមានចង្អុលទៅព្រឹត្តិការណ៍ជាក់ស្តែងនៃប្រវត្តិសាស្ត្រ គឺសង្គ្រាមវៀតណាមៗ ដូច្នេះមានចង្អុលទៅការអន្តរាគមរបស់សហរដ្ឋអាមេរិកនៅក្នុងតំបន់នេះៗ ដូច្នេះជាការត្រឹមត្រូវមួយហើយៗ

តើទន្ទឹមនឹងសង្គ្រាមវៀតណាមមានព្រឹត្តិការណ៍អ្វីទៀតទេ? គឺមានការបង្ក្រាបការបះបោររបស់កសិករនៅសំឡូតក្នុងថ្មុកឈាមៗ តើកសិករដែលគេបានអារក កាត់ក្បាលឳពុក ឬបងប្អូនសាច់ឈាមគេ ដុតផ្ទះសម្បែង និងភូមិករគេ ប្លន់ទ្រព្យសម្បត្តិគេ បានធ្វើឲ្យគេមានកំហឹងក្តៅឈួលអួលណែនក្នុងទ្រូងគេយ៉ាងណាទៅ? ដូច្នេះមានការដុតភ្លើងកំហឹងកសិករៗ បន្ទាប់មកមានរដ្ឋប្រហារទំលាក់សម្តេចនរោត្តម សីហនុ រំលាយនយោបាយអព្យាក្រឹតរបស់ជាតិ អូសកម្ពុជាឲ្យធ្លាក់ទៅក្នុងភ្លើងសង្គ្រាមវៀតណាមៗ ដូច្នេះមានការដុតភ្លើងកំហឹងស្រទាប់ផ្សេងទៀតក្នុងជាតិ ផ្គុំជាមួយកំហឹងកសិករឲ្យឆាបឆេះទ្រគុំទ្រគោលឡើងទៅជាកំហឹងជាតិទាំងមូល ដូចដែលមហាបាតុកម្មនៅកំពង់ចាម និងនៅតាកែវ បានបញ្ជាក់យ៉ាងពិស្តារបំផុតៗ

តើមានព្រឹត្តិការណ៍អ្វីផ្សេងទៀតទេ? គឺមានកម្លាំងតស៊ូវៀតណាមបុកទម្លាយចូលមកពាសពេញកម្ពុជាៗ គេចូលមក ដោយសារតែមានកម្លាំងសហរដ្ឋអាមេរិកដេញពីក្រោយទេៗ ប៉ុន្តែគេចូលមក គេចង់ធ្វើដូចជំនាន់មុនទៀត គឺគេចង់តាំងខ្លួនគេជាគ្រូបារអាចារ្យ និងជាអាណាព្យាបាលលើខ្មែរដូចមុនទៀតៗ សកម្មភាពរបស់គេ តែងជះឥទ្ធិពលអាក្រក់លើផ្ទៃក្នុងសង្គមខ្មែរ លើចលនាតស៊ូខ្មែរ ធ្វើឲ្យចលនាតស៊ូខ្មែរដែលមានជម្ងឺចាស់ ដែលធ្លាប់មានពីមុនស្រាប់មកផង គឺជម្ងឺពឹងផ្អែកលើវៀតណាមរើឡើងវិញសារជាថ្មីទៅជាមានការខ្វែងគំនិតគ្នាក្នុងចលនាអំពីវិធីតស៊ូៗ និន្នាការមួយយល់ថាតស៊ូល្មមៗបានហើយ ចាំដល់វៀតណាមឈ្នះគង់តែវៀតណាមមកជួយរំដោះទេៗ និន្នាការមួយទៀតដែលបានយល់ពីការលោភលន់របស់វៀតណាមច្បាស់ខំតស៊ូដោយខ្លួនឯង ដោយឯករាជ្យម្ចាស់ការៗ នេះហើយជាលក្ខណៈសម្បត្តិ នាំឲ្យវៀតណាមលូកដៃយ៉ាងជ្រៅចូលមកកកូរផ្ទៃក្នុងប.ក.ក ប្រមូលមនុស្ស ដែលគេកសាងបានកាលពីជំនាន់វៀតមិញវ៉ៃកម្លាំងដែលខិតខំតស៊ូដោយឯករាជ្យជាបន្តបន្ទាប់ រហូតដល់ក្រោយរំដោះប្រទេសបានហើយ ក៏គេនៅតែប្រើមនុស្សរបស់គេទាំងនោះបង្កើតភាពស្មុគស្មាញ ថែមលើភាពស្មុគស្មាញដែលមានស្រាប់នៅក្នុងប្រទេស ទន្ទឹមនឹងការដែលគេបុករុកពីក្រៅថែមទៀតៗ

បើយើងពិនិត្យចលនាខ្មែរក្រហមពីដើមទីមក យើងនឹងឃើញដំណើរមួយដ៏វែងឆ្ងាយខិតខំរំដោះខ្លួនពីអាណាព្យាបាល ដែលវៀតណាមគ្របដណ្តប់មកលើខ្លួនតាំងតែពីជំនាន់សង្គ្រាមជាមួយបារាំងមកម៉្លេះ ទាំងខាងមនោគមវិជ្ជា ទាំងខាងចាត់តាំងជាដំណើរមួយដ៏ព្យាយាមអំណត់អត់ធន់បំផុត ពីព្រោះចលនានេះយល់ច្បាស់ អំពីការចាំបាច់ត្រូវតែសាមគ្គីជាមួយបក្ស និងប្រជាជនវៀតណាមដើម្បីកុំឲ្យប៉ះពាល់ដលការតស៊ូប្រឆាំងសត្រូវរួម ដើម្បីរំដោះជាតិ ប៉ុន្តែដោយសភាពការណ៍នៅកម្ពុជាមិនដូចនៅវៀតណាម ហើយវៀតណាមក៏នៅតែទទូចបង្ខំឲ្យកម្ពុជា ដើរតាមផ្លូវដែលស្របនឹងផលប្រយោជន៍នៃការតស៊ូនៅវៀតណាម តែអាចនាំឲ្យអន្តរាយដល់ចលនាខ្មែរក្រហម ដូច្នេះខ្មែរក្រហមមិនព្រមធ្វើតាមវៀតណាមក៏យល់ថា ខ្មែរក្រហមមិនមែនជាសម្ព័ន្ធមិត្តមួយដែលអាចទុកចិត្តបានៗ នេះហើយជាឬសគល់នៃបញ្ហារវាងកម្ពុជា និងវៀតណាមៗ ដូច្នេះរហូតដល់ឆ្នាំ១៩៧៥ ចលនាខ្មែរក្រហមបានលេចឡើងជា

ចលនាស្នេហាជាតិដែលទទួលបានការគាំទ្រ និងសាមាន្យចិត្តពីជាតិ និងប្រជាជនយ៉ាងធំទូលាយ ដោយរួមមានទាំងប្រជាជនសឹងតែគ្រប់ស្រទាប់សង្គមក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តនានាផង។ ដូច្នេះមានពិសោធន៍ផ្តល់ជូនជាតិច្រើនណាស់។ ជាតិអាចរៀនសូត្រពិសោធន៍ ពីរយៈកាលជាប្រវត្តិសាស្ត្រនេះបានច្រើនណាស់។ មិនត្រូវបំភ្លេចចោលទេ។ បើមានកំហុសអ្វីក្រោយមកទៀត ក៏មិនអាចជាកំហុសប្រល័យពូជសាសន៍ឯងទៅកើតទេ។ គួរយើងយកកំហុសនោះមកពិនិត្យឲ្យបានហ្មត់ចត់ដែរ។ ពីព្រោះចលនាមួយដែលតស៊ូទទួលបានជ័យជម្នះ ទាំងលើមហាអំណាចធំ ដូចជា សហរដ្ឋអាមេរិក ទាំងលើមហាអំណាចមធ្យម ដូចជាវៀតណាមមិនឲ្យមហាអំណាចនេះយកកម្ពុជាទៅបញ្ចូលក្នុងរង្វង់សហព័ន្ធឥណ្ឌូចិនរបស់ខ្លួនបាន មានន័យថា ចលនានេះជាចលនាស្នេហាជាតិមិនគ្រាន់តែក្លាហានមោះមុតទេ គឺថែមទាំងមានសមត្ថភាពរៀបចំយុទ្ធសាស្ត្រមួយ ហើយមានសមត្ថភាព អនុវត្តយុទ្ធសាស្ត្រនេះទទួលបានជ័យជម្នះទៀតក្នុងសភាពការណ៍ ដែលការប្រៀបធៀបកម្លាំងខុសគ្នាឆ្ងាយយ៉ាងនេះ។

ស្រាប់តែក្រោយឆ្នាំ១៩៧៥ គេបែរជាមាននយោបាយមួយ ដែលហាក់ដូចជាប្រឆាំងនឹងប្រជាជននៅទីក្រុង និងទីរួមខេត្តទៅវិញ។ តើមកពីមូលហេតុអ្វី? យើងនឹងសាកល្បងពិនិត្យបញ្ហានេះ។

ដូច្នេះ យើងនឹងបែងចែកជំពូក៥នេះ ជាពីរផ្នែកធំ ៖

ផ្នែកទីមួយ ពិនិត្យប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជារហូតដល់ឆ្នាំ១៩៧៥។

ផ្នែកទីពីរ សាកល្បងពិចារណានិងស្រាវជ្រាវរកចម្លើយ និងសំនួរមួយចំនួនដែលបានលេចឡើង ក្រោយឆ្នាំ១៩៧៥។

ពិតមែនតែខ្ញុំមិនមែនជាអ្នកប្រវត្តិសាស្ត្រ ហើយខ្ញុំមិនមានលទ្ធភាពទៅស្រាវជ្រាវដោយផ្ទាល់ខ្លួនខ្ញុំ ខ្ញុំយល់ថា ខ្ញុំអាចឈានទៅសម្រេចទិសដៅខាងលើនេះបាន ដោយផ្អែកលើទស្សនៈរួមរបស់ខ្ញុំចំពោះចលនានេះផង ហើយ



អ្វីដែលខ្ញុំមិនដឹង ខ្ញុំបំពេញដោយលទ្ធផលដែលអ្នកស្រាវជ្រាវបានរកឃើញផង។ ពិតមែនហើយអ្នកស្រាវជ្រាវមានការភ័ន្តច្រឡំច្រើនដែរ ហើយការភ័ន្តច្រឡំនោះមិនមែនតូចតាចទេ ប៉ុន្តែអ្វីដែលគេបានរកឃើញក៏មានតម្លៃណាស់ដែរ។

ខ្ញុំមានជំនឿលើទស្សនៈរួមរបស់ខ្ញុំចំពោះចលនានេះ ដោយខ្ញុំសំអាងលើហេតុផលពីរ:

**ទី១**-ខ្ញុំបានធ្វើដំណើរជាមួយចលនានេះ អស់រយៈ៣០ឆ្នាំហើយ ខ្ញុំបានឆ្លងកាត់ការបត់បែន ពេលខ្លះប្រកបទៅដោយគ្រោះថ្នាក់ស្លាប់រស់ជាមួយគេច្រើនលើកច្រើនសារ។

**ទី២**-ខ្ញុំស្គាល់ដោយផ្ទាល់មុខវីរបុរស ដែលគេមិនស្គាល់មុខទាំងនោះជាច្រើន ដែលជាកម្មាភិបាល យុទ្ធជន យុទ្ធនារីជាកូន ចៅកសិករ គួរជាទីគោរព ហើយដែលបានពលីកម្មទៅដើម្បីបុព្វហេតុជាតិ និងបុព្វហេតុនៃយុត្តិធម៌សង្គម ដែលគេគោរព និងស្រឡាញ់ចង់បានបំផុត។

# ភាគទី១

## ប្រវត្តិដើមនៃបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) រហូតមកដល់ឆ្នាំ១៩៧៥

ក្នុងភាគទីមួយនេះ ខ្ញុំនឹងរៀបរាប់ល្អិត អំពីការខិតខំពុះពារកសាងបក្សមួយឯករាជទាំងខាងមនោគមន៍វិជ្ជា ទាំងខាងមាគ៌ានយោបាយ ទាំងខាងចាត់តាំងកម្លាំង ដោយហ្វឹកហ្វឺនកសិករប្រយុទ្ធលើសមរភូមិជាក់ស្តែង តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៥០ ដើមទសវត្សរ៍ឆ្នាំ១៩៦០ជាបន្តបន្ទាប់រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០។ អានទៅហាក់ដូចជាខ្ញុំគាំទ្រអំពើហឹង្សាតាំងពីការសម្លាប់មេឃុំ មេព្រៃ មេនេសាទៗល។ រហូតដល់សង្គ្រាមស៊ីវិល។ ការពិតខ្ញុំចង់បង្ហាញថាតើមេៗខ្មែរក្រហម ធ្វើយ៉ាងណាដើម្បីគាស់កម្លាំងកសិករខ្មែរដែលធ្លាប់តែបាក់បបខ្ចបខ្ចាច "គេអ្នកធំ" ឲ្យទៅជាកម្លាំងតស៊ូមួយចេះតស៊ូដោយខ្លួនឯង ដោយឯករាជពីវៀតណាម។ ខ្ញុំដឹងរឿងទាំងអស់នេះដោយបានអានឯកសារ និងដោយកម្មាភិបាលនៅនិរតីនិយាយប្រាប់ខ្ញុំ។ ការពិតទៅ នៅចិនក្តី នៅវៀតណាមក្តី ក៏មេៗដឹកនាំបដិវត្តន៍ធ្វើដូច្នេះដើម្បីឲ្យកសិករចេះ "តស៊ូវណ្ណៈ" ហើយក្លាយទៅជាកម្លាំងបដិវត្តន៍ មួយដ៏ខ្លាំងក្លា។ តែពេលកម្លាំងវៀតមិញចូលមកកម្ពុជា ពួកគេមិនបានហ្វឹកហ្វឺនឲ្យកសិករខ្មែរចេះតស៊ូដោយខ្លួនឯងទេ។ គេទុកឲ្យខ្មែរនៅចាំតែពឹងផ្អែកលើគេ ចាំតែធ្វើកូនទាហានរបស់គេ ស្រេចតែគេប្រើឲ្យទៅច្បាំងស្លាប់ បម្រើយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់គេតែប៉ុណ្ណោះ។ យើងបានឃើញក្នុងជំពូកទី៣ ហើយ អ្នកតស៊ូខ្មែរខ្លះគេលើកបន្តុបឲ្យធ្វើជាមេបញ្ជាការ តែស្រេចតែវៀតណាមជាអនុបញ្ជាការទេជាអ្នកបញ្ជាចាត់ចែងទាំងអស់។ អ្នកខ្លះក៏មិនសប្បាយចិត្តដែរ តែអ្នកខ្លះក៏សប្បាយចិត្តនិងបាន "ធ្វើធំ" ដោយមិនបាច់តស៊ូ។ ហេតុដូច្នេះហើយបានជាកម្មាភិបាលដែលចេញមកពីជំនាន់ហៅថា "សង្គ្រាម៩ឆ្នាំ" នោះ ទទួលឥទ្ធិពលពីវៀតណាមខ្លាំងណាស់ ពីព្រោះការខិតខំតស៊ូដោយ



"ឯករាជម្ចាស់ការ" ដូចយើងនឹងឃើញខាងក្រោមនេះ ទាមទារការទ្រាំទ្រលំបាកវេទនានិងពលិកម្មខ្លាំងណាស់។ តែបើមិនបានពុះពារខិតខំកសាងបក្សមួយឯករាជពីវៀតណាម ដោយឈរលើកម្លាំងកសិករកម្ពុជាទេ ម៉្លេះកម្ពុជាធ្លាក់ទៅក្នុងកណ្តាប់ដៃវៀតណាម តាំងពីក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ទៅហើយ។ មិនមានការចរចា និងកិច្ចព្រមព្រៀងប៉ារីសទេ មិនមានអ៊ុនតាក់ មិនមានកម្ពុជាបច្ចុប្បន្ននេះទេ។

ហេតុនេះហើយបានជាខ្ញុំសូមរៀបរាប់ជូនដូចតទៅ។ ការរៀបរាប់របស់ខ្ញុំនេះភាគច្រើន គឺរៀបរាប់តាមសៀវភៅអ្នកស្រាវជ្រាវ ដូចខ្ញុំនឹងជម្រាបឈ្មោះ និងចំណងជើងជាបន្តបន្ទាប់ជាមួយនេះផងដែរ។

### ក-ក្រោយពីវៀតមិញចេញផុតទៅអ៊ីៗ ដែលគេចាត់តាំងទុកឲ្យខ្មែរត្រូវរលាយខ្សុល

មូលហេតុមាន ៣ ៖

- មូលហេតុទី១ គឺមកពីការរាតត្បាតដោយស្ងាត់ៗពីសំណាក់រដ្ឋអំណាចរបស់ ព្រះករុណាព្រះបាទនរោត្តម សីហនុ។
- មូលហេតុទី២ គឺមកពីវៀតណាមខ្លួនឯង ដែលជាអ្នកបង្កើតចលនានេះ ជាប់រវល់ខ្លាំងពីបញ្ហាជាច្រើនលើសលុប។

"គណកម្មាធិការការងារ" មួយ ក៏បានត្រូវបង្កើតឡើងដោយការិយាល័យផ្នែកខាងត្បូងដែរ ដែលថ្ងៃក្រោយនឹងបានក្លាយទៅជាមន្ទីរមជ្ឈិមផ្នែកខាងត្បូង ដើម្បីទាក់ទងឲ្យជាប់ជាមួយខ្មែរដែរ។[៧៤] ប៉ុន្តែដល់ចុងឆ្នាំ១៩៥០ មានការរាតត្បាតខ្លាំងពីរដ្ឋអំណាចង៉ោ ឌិនឌៀម ហើយ "គណកម្មាធិការការងារ" នោះជាប់រវល់ខ្លាំងខាងកិច្ចការពារអ្នកដឹកនាំគេ។

[៧៤] ហ្វីលិព ហ្សូត-ប៉ុល ពត...- ទំព័រ១២១

ពេលនិយាយពីរឿងនេះនៅពេលក្រោយមកលោកសាឡុតស បានថា នេះជាឱកាសល្អសម្រាប់យើង "ព្រោះនាំឲ្យយើងស្រឡះដៃ ហើយអាចពង្រីងពង្រីកចលនាដោយខ្លួនយើងបាន"។ ការពិតសម្រាប់ជនកុម្មុយនីស្តមួយក្រុមតូច ខិតខំរស់នៅដោយត្រដាបត្រដួសដោយខ្លួនឯង ក្នុងរបបមួយដែលខ្លួនទើបតែប្រយុទ្ធ ដោយអាវុធមិនមែនងាយដូចមាត់គាត់ថានោះទេ។

- មូលហេតុទី៣ គឺមូលហេតុជាមូលដ្ឋាន។ គឺមកពីវិបត្តិនៃអត្តសញ្ញាណរបស់បក្ស ដែលវៀតណាមបានចាត់តាំងទុកឲ្យខ្មែរតែម្តង។ តើហៅគេថាជាជនកុម្មុយនីស្តធ្វើម៉េចកើត បើគេជាសមាជិកនៃបក្សមួយដែលមិនមែនជាបក្សកុម្មុយនីស្តផង។ នៅឆ្នាំ១៩៥១ លក្ខន្តិកៈនៃបក្សចែងច្បាស់ថា ទិសដៅគឺ "ធ្វើការតស៊ូយ៉ាងម៉ឺងម៉ាត់ដាច់ខាត ដើម្បីកំទេចអាណានិគមនិយមបារាំង ចក្រពត្តិអាមេរិក និង បរិវា"[៧៥]។ ក្រោយឆ្នាំ១៩៥៤ សមាជិកភាគច្រើននៃបក្សនេះក៏យល់ថា ភារកិច្ចរបស់គេបានចប់សព្វគ្រប់ហើយ ពីព្រោះប្រទេសបានឯករាជ្យហើយ គេក៏ត្រឡប់ទៅផ្ទះវិញ។

ពេលគាត់និយាយពីសភាពការណ៍ទូទៅនៅពេលនោះ បែន គៀរណាន់ សរសេរថា "រយៈកាលនោះ មានលក្ខណៈគួរឲ្យកត់សម្គាល់នៅត្រង់ការវិវត្តដែលគេមិនបានប៉ាន់ស្មានមុន តែទាំងអស់គ្នារីករាយពេញចិត្តនូវគោលជំហរកាន់តែឯករាជ្យឡើងៗ របស់សម្តេច សីហនុ ការបាត់នូវសន្ទុះទឹកចិត្តខាងបដិវត្តន៍ដែលបណ្តាលមកពីការចាញ់ឆ្នោតផង និងពីការដែលមិនបានត្រៀម នូវស្មារតីតស៊ូវណ្ណៈផង។"[៧៦]

[៧៥] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៧១

[៧៦] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៧១



អំពីការវិវត្តិរបស់សម្តេចព្រះនរោត្តម សីហនុយើងបាននិយាយហើយនៅជំពូកទី៤។ ប៉ុន្តែអ្វីដែលខ្ញុំចង់គូសបញ្ជាក់ គឺពាក្យរបស់លោកបែន គៀរណាន់ ដែលលោកនិយាយអំពីមូលហេតុនៃការបាត់ស្មារតីរបស់អ្នកតស៊ូចាស់ និងអំពីបក្សកម្ពុជាដែលវៀតណាមបានបង្កើតនៅពេលនោះ។ ពាក្យមួយម៉ាត់ពីរម៉ាត់នេះរបស់លោកបែន គៀរណាន់បញ្ជាក់ច្បាស់ថា វៀតណាមមិនត្រូវការឲ្យខ្មែរដែលតស៊ូជាមួយគេពេលនោះ សូម្បីតែកម្មាភិបាលសំខាន់ៗក៏ដោយ យល់ដឹងអ្វីទាំងអស់ ចាំតែធ្វើតាមបង្គាប់គេតែប៉ុណ្ណោះ។ បក្សក៏មិនដឹងជាបក្សអ្វី។ ថា ជាបក្សបដិវត្តិវតន៍តែ" មិនបានត្រៀមនូវស្មារតីតស៊ូវណ្ណៈ" ឲ្យសមាជិក។ ចេញជាលទ្ធផល គឺអស់ពីពួកកុម្មុយនីស្តវៀតណាមទៅ គេមិនដឹងធ្វើអ្វីទាំងអស់។ គេបានតស៊ូវាយរបបមួយដោយអាវុធ ក្រោយមកកាលៈទេសៈតម្រូវឲ្យគេដាក់អាវុធចុះ ហើយគេត្រឡប់ទៅដេកផ្ទះវិញ។ នេះបានចំជាឆោតល្ងង់។

កាលពីឆ្នាំ១៩៥៤ នៅពេលដែលខ្មែរអ្នកតស៊ូរាប់ពាន់នាក់ស្លៀកពាក់ឯកសណ្ឋានវៀតមិញ ឡើងកប៉ាល់ទៅហាណូយជាមួយគេ មិនដឹងខ្លួនថាតើខ្លួនទៅទីនោះដើម្បីធ្វើអ្វីនោះផងទេ។ សូម្បីតែលោក ស៊ិន ង៉ុកមិញ ដែលគេបានប្រកាសជាឧឡាឬក រួចមកហើយថាជាបិតាបដិវត្តន៍កម្ពុជា ក៏ទៅហាណូយដែរ។ តើមេអ្នកដឹកនាំបដិវត្តន៍ជាតិមួយ ដែលទៅនៅដាច់ពីប្រទេសយ៉ាងនេះ ដឹកនាំបដិវត្តន៍ក្នុងប្រទេសខ្លួនយ៉ាងម្តេចទៅ។ ឯលោកសីវហេង ដែលគេចាត់តាំងជាលេខាបក្សក្រោយពីលោក ស៊ិន ង៉ុក មិញ សម្រេចទៅហាណូយ ក៏យល់ថាក្រោយដែលប្រទេសបានឯករាជ្យ ហើយមិនមានហេតុផលអ្វីនឹងតស៊ូទៀតទេ។ លេខាបក្សយល់យ៉ាងនេះ តើបក្សនោះជាស្អីទៅ? ទីចុងបំផុត ក៏ទៅសារភាពលោកលន់ នល់។ បើលេខាបក្ស "បដិវត្តន៍មួយសារភាពទៅហើយ តើនៅសល់អ្វីទៀត"?

ឯលោកសាឡុតស លោកមី ម៉ាន់ និងលោកចាន់ សាម៉ន មិនទៅណាជាមួយគេទេ។ គាត់ចេញដំណើរពីក្រៅជាមួយផាំ វ៉ាន់បា តំណាងជើង

ថាញ់សឺង នៅក្នុងគណៈកម្មាធិការត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងហ្សឺណែវនៅកម្ពុជាហៅថា "សេអ៊ីសេ" និងប្រពន្ធ ដើម្បីត្រឡប់មកភ្នំពេញវិញ ដោយដើរតាមផ្លូវធ្វើហាក់ដូចជាទៅចូវដុកនិងគេដែរ តែរៀងបត់បែនក្រងិកក្រង៉ុកឡើងចុះដើម្បីបង្វែងដាន។ ពីមុនហូរហែមកឈ្មោះផាំ វ៉ាន់បានេះតែងតែអប់រំខ្មែរថា ប្រជាជនកម្ពុជា លាវ និងវៀតណាមសាមគ្គីគ្នាដូចបងប្អូនបង្កើត និងធ្មេញ។ ឥឡូវនេះនៅតាមផ្លូវគេប្រាប់មិត្តភក្តិទាំបីនាក់ថា "ការតស៊ូអាវុធចប់ហើយ ពួកមិត្តត្រូវតស៊ូនយោបាយវិញ"។ ពាក្យនេះដូចជាគួរឲ្យស្ដាប់បានដែរ។ តែគេត្រូវធ្វើអ្វីខ្លះ មិត្តទាំងបីនាក់ជជែកគ្នាចប់តែផ្លូវ រកឆ្លើយមិនបានសោះ។

នៅរវាងចុងឆ្នាំ១៩៥៥ អ្នកដឹកនាំកុម្មុយនីស្តវៀតណាម ក៏បានធ្វើការណែនាំមួយមកបក្សខ្មែរជាផ្លូវការ។ ការណែនាំនេះរំលឹកថា ការតស៊ូអាវុធចប់ហើយ។ ខ្មែរត្រូវបន្ត "តស៊ូនយោបាយ"។

ការណែនាំនេះជាឧទាហរណ៍ទី១ នៃឱកាសនិយមនៃបក្សពលករវៀតណាម។ ក្រោយជ័យជម្នះរបស់សម្ដេចនរោត្តម សីហនុ ក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ ពួកកុម្មុយនីស្តវៀតណាមសន្និដ្ឋានភ្លាមថា គេមានតែខាត ហើយគ្មានអ្វីចំណេញទាល់តែសោះ បើគេនៅបន្តគាំទ្រខ្មែរ ដែលបានដើរតាមគេអស់រយៈជាច្រើនឆ្នាំមកហើយ កាលពីសង្គ្រាមប្រឆាំងបារាំង។ ដូច្នេះគេភ័យតែមួយមុខទេ។ គឺគេភ័យខ្លាចតែអ្នកតស៊ូខ្មែរទ្រាំនឹងការរាតត្បាតរបស់សម្ដេចនរោត្តម សីហនុមិនបាន ទ្រាំនឹងជីវិតរស់នៅដូចសត្វឈ្លុះរត់ពួនតែក្នុងព្រៃចោលប្រពន្ធចោលកូន មិនហានចូលភូមិត្រឡប់មកតស៊ូអាវុធវិញ។

ការដែរគួរឲ្យអស់សំណើចគឺថា មុននឹងផ្ញើសំបុត្រណែនាំនេះមកឲ្យខ្មែរ អ្នកដឹកនាំកុម្មុយនីស្តវៀតណាមមិនបានយកចិត្តទុកដាក់សួរនាំ អំពីសភាពការណ៍របស់គេនៅនឹងកន្លែងទេ។ សូម្បីតែមួយម៉ាត់ក៏គ្មានផង។ ដូច្នេះបក្សខ្មែរខ្វាត់ខ្វាយរប៉ាត់រប៉ាយយ៉ាងណាក៏ដោយ ក៏គេមិនរវល់ចង់ដឹងចង់ឮផងទេ។ ចំពោះគេ ខ្មែរនៅក្រោមបង្គាប់គេហើយ គ្មានសិទ្ធិនិយាយអ្វីទាំងអស់។



តៗទៅមុខទៀតយើងនឹងឃើញទស្សនៈបែបនេះ អាកប្បកិរិយាបែបនេះកាន់តែច្បាស់ឡើងៗ។

ប្រហែលជាលោកគិតដល់ការណែនាំនេះហើយ បានជាលោកដេវិត ឆាន់ទ្លែរសរសេរការកត់សម្គាល់ដូចខាងក្រោមនេះ "គឺរយៈពេលនោះហើយ ដែលពួកកុម្មុយនីស្តវៀតណាម ផ្ដល់ដំបូន្មានដល់សហការីខ្មែររបស់គេឲ្យ "តស៊ូនយោបាយ" ដែលក្នុងការជាក់ស្ដែង គឺដូចជានាំសកម្មជនរបស់គេមកបង្ហាញប៉ូលីស"។[៧៧] ហើយលោកក៏មានមតិថា សូម្បីតែយ៉ាងនេះក៏ខ្មែរចេះតែគោរពតាមដែរ។ ការពិតទៅបក្សខ្មែរនោះរលាយអស់ទៅហើយ។ ឯសមាជិកសូម្បីតែមកអើតក្បែរភូមិក៏មិនហានផង។

នៅពេលនោះ លោកទូសាមុទ អ្នកទី២នៅក្នុងគណៈកម្មាធិការមជ្ឈឹមបណ្ដោះអាសន្ន ដែលពួកវៀតមិញបានចាត់តាំងឡើងមុននឹងគេចាកចេញពីកម្ពុជានោះ ក្រោយពីបានរង់ចាំឲ្យព្យុះសង្ឃរានៃការឃោសនាបោះឆ្នោតបានស្ងប់បន្តិចក៏លបលួចចូលមកភ្នំពេញ។ គាត់មកនៅក្នុងខ្ទមមួយតូចដែលលោកសាឡុតស បានសង់ទុកជូនគាត់នៅលើដីមួយរបស់ម្ដាយលោកស្រីប៉ុណ្ណារី ប្រពន្ធរបស់គាត់នៅទួលស្វាយព្រៃខាងនារតីរដ្ឋជាទី។[៧៨]

គាត់ជាសមាជិកតែម្នាក់គត់ ដែលសកម្មក្នុងចំណោមសមាជិក៥នាក់នៃគណៈកម្មាធិការមជ្ឈឹមបណ្ដោះអាសន្ននៃបក្សខ្មែរ ដែលពួកវៀតមិញបានចាត់តាំងមុននឹងពេលដែលគេចេញពីស្រុកខ្មែរ។ ជាគោលការណ៍គាត់ត្រូវធ្វើជាប្រធានគណៈកម្មាធិការក្រុងរបស់បក្ស ដែលតាំងពីដំបូងដែមកមានលោក នួន ជា ដែលគាត់មកជំនួសលោកកែវ មាស ដែលត្រូវទៅធ្វើជាបេក្ខជនរបស់ក្រុមប្រជាជន -និងលោកសាឡុតស លោកម៉ុ ម៉ាន់ និង លោកចាន់ សាម៉ន។ ប៉ុន្តែមួយរយៈទៅលោកម៉ុ ម៉ាន់ និងលោក ចាន់ សាម៉ន ក៏

[៧៧] ដេវិត ឆាន់ទ្លែរ "បងធំទីមួយ" ទំព័រ៥៦

[៧៨] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១១៩, ដេវិត ឆាន់ទ្លែរ "បងទីមួយ" ទំព័រ ៥២

បោះបង់ចោលការងារនេះ។ ដូច្នេះនៅសល់តែ៣នាក់ គឺទូ សាមុទ សាឡុតស និងនួន ជា។

ដោយសារគាត់ធ្លាប់ទទួលការអប់រំតាមព្រះពុទ្ធសាសនា និងមានអត្តចារិតហ្នឹងហ្នរ គាត់បានទទួលសមានចិត្តពីលោកទូ សាមុទ្ទ ចាប់តាំងពីគាត់ជួបគ្នាលើកដំបូងម៉្លេះនៅក្រៅ។ តាមការសុំពីលោក ទូ សាមុទ លោកសាឡុតស ក៏ចាប់ផ្តើមទៅជាអ្នកជំនួយការរបស់លោក ជួយគាត់រៀបចំការអប់រំរៀនសូត្រខាងនយោបាយដល់កម្មាភិបាល។ បណ្តើរៗទៅដោយសឹងតែមិនដឹងខ្លួនផង ស ក៏ក្លាយទៅជាលេខារបស់តាទូ សាមុទ និងអ្នកជំនួយការសំខាន់របស់គាត់ រហូតដល់៥ឆ្នាំតទៅទៀត។[៧៩]

នួន ជា បានចូលមកក្នុងចលនាកុម្មុយនីស្តតាមផ្លូវមួយ ដែលខុសពីអ្នកដទៃផ្សេងទៀតទាំងអស់។ គាត់មានអាយុពីរឆ្នាំបងលោកសាឡុតស ហើយគាត់បានធំធាត់នៅបាត់ដំបង។ នៅពេលដែលខេត្តនេះបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ថៃក្នុងរវាងឆ្នាំ៤០ គាត់ទៅរៀនមធ្យមសិក្សានៅបាងកក ហើយធ្វើការតូចតាចនៅក្នុងក្រសួងការបរទេសប្រទេសថៃមួយរយៈ មុននឹងមកចុះឈ្មោះនៅសាកលវិទ្យាល័យធម្មសាត្រ ដែលនៅទីនោះគាត់រៀនច្បាប់។ ពេលនោះក៏គាត់ចូលជាសមាជិកបក្សកុម្មុយនីស្តថៃ ប៉ុន្តែក៏ឈប់នៅរវាងចុងឆ្នាំ១៩៤០ ដើម្បីមកតាមបងជីដូនមួយគាត់ឈ្មោះ ស៊ីវ ហេង នៅទីបញ្ជាការរបស់ភូមិភាគពាយ័ព្យនៅលើភ្នំក្នុងស្រុកសំឡូត មិនឆ្ងាយប៉ុន្មានពីប៉ៃលិនទេ។ ពេលនោះគាត់ត្រូវគេផ្ទេរទៅឲ្យទៅបក្សកុម្មុយនីស្តឥណ្ឌូចិន ហើយនៅខែកញ្ញាឆ្នាំ១៩៥១ គាត់ក៏ត្រូវគេចាត់តាំងជាសមាជិកនៃគណៈកម្មាធិការមជ្ឈឹមនៃបក្សបដិវត្តន៍ប្រជាជនកម្ពុជា ដែលគេទើបបានបង្កើត។ ក្រោយបន្តិចមកគាត់ ក៏ត្រូវបានបញ្ជូនឲ្យទៅរៀននៅសាលាជាន់ខ្ពស់បំផុតនៃបក្សនៅវៀតណាម។ នៅឆ្នាំ១៩៥៥ គាត់ក៏ត្រឡប់មកកម្ពុជាវិញ ដោយលួច

[៧៩] ហ្វីលិព ហ្សត-"ប៉ុល ពត..." ទំព័រ ១០០



លាក់ ហើយរកបានការធ្វើនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មមួយ ដែលបានក្លាយទៅជាជំរករបស់គាត់បានយូរជាងគេ នៅពេលដែលសហការីរបស់គាត់ត្រូវរត់ចូលព្រៃមុនគាត់ជាបន្តបន្ទាប់។[៨០]

**ខ-ឆ្ពោះទៅរកការបង្កើតបក្សខ្មែរមួយដែលជាសម្ព័ន្ធមិត្ត តែមិននៅក្រោម បង្គាប់វៀតណាមទៀតទេ។**

ចាប់ពីឆ្នាំ១៩៥៧មក អ្នកទាំង៣នាក់ តែងជួបគ្នាជាទៀងទាត់នៅផ្ទះលោកទូ សាមុទ ពីរ ឬបីដងក្នុងមួយអាទិត្យ ដើម្បីពិភាក្សាគ្នាពីសភាពការណ៍នយោបាយ និងដើម្បីរកមធ្យោបាយធ្វើឲ្យចលនាមុនកម្រើកឡើងវិញ។ ក្នុងការងារនេះ លោក ទូ សាមុទ្ទ ខិតខំមិនខ្លាចនឿយហត់ទេ។

ប៉ុន្តែការទាក់ទងរវាងអ្នកនៅភ្នំពេញ និងបណ្តាញផ្សេងៗនៅជនបទជួបការលំបាកយ៉ាងខ្លាំង ដោយសារតែការរាតត្បាត និងការបាត់ស្មារតីរបស់អ្នកតស៊ូចាស់។

អ្នកខ្លះរត់ទៅនៅក្នុងព្រៃឆ្ងាយពីភូមិ។ ក្នុងករណីខ្លះ ទំរាំភ្ជាប់ជាមួយបក្សបានវិញត្រូវដាច់គ្នារាប់ឆ្នាំ។ ឧទាហរណ៍នៅឆ្នាំ១៩៦០ លោកសាឡុតសត្រូវទៅស្វែងរកជួបអ្នកតស៊ូចាស់នៅក្នុងព្រៃក្នុងស្រុកក្រូចឆ្មារ។ គេរស់ដោយសារតែដុត ធ្យូងលក់ទេ។

ដោយសារមូលហេតុនេះ អ្នកដឹកនាំទាំង៣ក៏យល់ស្របគ្នាថា ចាំបាច់រៀបចំកម្មវិធីនយោបាយថ្មី និងលក្ខន្តិកៈមួយថ្មី ដើម្បីបង្កើតបក្សខ្មែរថ្មីមួយជំនួសបក្សចាស់ ដែលនៅជាសម្ព័ន្ធមិត្ត តែមិននៅក្រោមបង្គាប់វៀតណាមទៀតទេ។

កត្តាមួយសំខាន់ដែលនាំឲ្យចេញគំនិតនេះឡើង ប្រហែលមកពីនៅពេលនោះសាលាចម្រើនវិជ្ជា ដែលលោកសាឡុតសបង្រៀនតាំងពីគាត់ចេញពី

[៨០] ហ្វីលិព ហ្សត-"ប៉ុល ពត..." ទំព័រ ១២០

ព្រៃមក ហើយសាលាចម្រើនពីរទៀតនៅរាជធានី គឺកម្ពុជាបុត្រ និងសុតន់ប្រីជាឥន្ទ បានទាក់ទាញកូនសិស្សកាន់តែច្រើនឡើងៗ ដែលមានសមាន្យចិត្តជាមួយនឹងបុព្វហេតុនៃការតស៊ូ។ ស្ទូលចាប់ផ្តើមលេចចេញជាបណ្តើរៗ។

ស្ទូលនេះមានទាំងនៅក្នុងសាលារដ្ឋដូចជា វិទ្យាល័យស៊ីសុវត្ថិ សាលាគុរុកុសល ព្រមទាំងសមាគមនៃសិស្សចាស់នៃសាលាទាំងនោះ។ លោក បែន គៀរណាន់សរសេរថាៈ "នៅក្នុងរយៈ១០ឆ្នាំទៅមុខទៀតនេះ សិស្សដែលចេញមកពីសាលាទាំងបីនេះ បានផ្តល់ភាគច្រើននៃសកម្មជនខាងឆ្វេងក្នុងប្រទេស។ អ្នកទាំងនោះ ភាគច្រើនជាគ្រូបង្រៀនក្នុងសាលានៅជនបទ ហើយបានខិតខំធ្វើឲ្យសិស្សនៅទីនោះភ្ញាក់រលឹកខាងនយោបាយ..... ប៉ុន្តែអ្វីដែលសំខាន់ជាងគេនៅពេលនោះ គឺដោយសារតែសាលាទាំងនោះហើយ ដែលពួកកុម្មុយនីស្តខ្មែរចាប់ផ្តើមចូលក្នុងគ្រួសារអ្នកកណ្តាលនៅភ្នំពេញ។ ដូច្នេះទន្ទឹមនឹងឥទ្ធិពលរបស់ពួកកុម្មុយនីស្តដែលនៅសល់ខ្លះ នៅកន្លែងខ្លះក្នុងជនបទកាលពីពេលសង្គ្រាមនៅក្នុងរាជធានី គឺនៅមជ្ឈដ្ឋាននេះហើយដែលមនោសញ្ចេតនាប្រឆាំងស្តេច (នៅក្នុងភាសាពួកកុម្មុយនីស្តគេហៅថា ប្រឆាំងសក្តិភូមិ) ខ្លាំងជាងគេ។ មនោសញ្ចេតនានេះ កើតមានឡើងមួយផ្នែកមកពីព្រឹត្តិការណ៍នៅក្នុងពេលបោះឆ្នោតឆ្នាំ១៩៥៥ និងមកពីការរំលាយគណបក្សប្រជាធិបតេយ្យ។ មួយផ្នែកទៀត ក៏អាចមកពីកន្លែងនេះទុកចំហរចោលឲ្យពួកកុម្មុយនីស្តដោយសារតែលោក សឺង ង៉ុកថាញ់ មិនព្រមចូលភ្នំពេញហើយទៅចងសម្ព័ន្ធភាពកាន់តែចំហរឡើងៗជាមួយសហរដ្ឋអាមេរិក និងដោយសារតែឱកាសនិយមនៃអ្នកដឹកនាំបក្សប្រជាធិបតេយ្យខ្លះ ដែលបានរត់ចូលសង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ និងដោយសារតែអ្នកខ្លះផ្សេងទៀតអសកម្ម មានជាអាទិ៍ ប៉ាច ឈឺន គាត់ទៅធ្វើជាចាងហ្វាងបណ្ណាល័យជាតិ។ ចំណែកឯលោកកេងវ៉ាន់សាក់វិញលោកយល់ថា ការផ្លាស់ប្តូរខាងនយោបាយទៅមិនរួចទេពីព្រោះតាមលោកយល់ "ខ្មែរខ្លាចស្តេចពេក"។ គាត់ក៏ដូចគេឯងផ្សេងទៀតដែរក៏បោះបង់ចោលសកម្មភាពនយោបាយ ហើយ



ងាកទៅខិតខំព្យាយាមកែប្រែវប្បធម៌ ដោយគាត់សង្ឃឹមថា ជាបណ្តើរៗទៅនឹងកែប្រែ "របៀបគិតគូរ" របស់ប្រជាជន ហើយនឹងផ្តល់មូលដ្ឋាននៃនយោបាយទំនើប"។[៨១]

ដូច្នេះតាំងពីខែមិថុនា-កក្កដា ឆ្នាំ១៩៥៧មក ចលនាមិនទាន់រីកស្គុះស្គាយនៅឡើយទេ -តែក៏ឈប់ធ្លាក់ចុះតទៅទៀតដែរ យ៉ាំងហោចណាស់នៅភ្នំពេញ។[៨២] ប្រហែលចាប់ពីពេលនោះមកហើយ ដែលលោក ទូ សាមុទ និងលោក នួន ជា ចាប់ផ្តើមយល់ពីតួនាទីនៃចលនាថ្មីនេះហើយ ចាប់ផ្តើមយល់ថាឈាមថ្មីនេះ អាចជួយផ្តល់ជាកម្លាំងស្មារតីដល់អតីតកម្មាភិបាលកសិករដែលពេលនោះ កំពុងតែទ្បេទ្បា ហើយអស់សង្ឃឹម។

ឯចំពោះពួកកុម្មុយនីស្តខ្មែរវិញ ទំនាស់សង្គមឬនយោបាយដែលកើតមានឡើងជាប្រចាំថ្ងៃ ជាថ្នាលដើម្បីហ្វឹកហ្វឺនស្ទូលថ្មីជាបន្តបន្ទាប់ ឲ្យចេះដឹកនាំមហាជនតស៊ូ។ គេដឹកនាំមហាជនតស៊ូពីទាបទៅខ្ពស់ ហើយកាន់តែខ្ពស់ឡើងៗ មិនខ្លាចគ្រោះថ្នាក់។ ទើបគេជ្រើសរើសអ្នកដែលបានសាកល្បងរួចហើយ ឲ្យចូលជាសមាជិកបក្ស។ នេះហៅថា "កសាងបក្សក្នុងចលនា"។ ថែមពីលើនេះទៀតគេយកចិត្តទុកដាក់គួសបញ្ជាក់ឲ្យស្ទូល ដែលចេញមកពីនិសិត្ស ឬគ្រូបង្រៀនទាំងនោះឲ្យយល់ច្បាស់ថា កសិករទេដែលជាកម្លាំងអាចដឹកនាំបដិវត្តន៍ឲ្យទទួលជ័យជម្នះបាន ពិសេសកសិករក្រ។ ដូច្នេះគេត្រូវខំជិតស្និទ្ធជាមួយកសិកររាបសារជាមួយគេឲ្យគេជឿយើងថា យើងជាមិត្តស្មើភាពជាមួយគេ ដើម្បីយើងបំភ្លឺគេឲ្យគេឃើញកម្លាំងរបស់គេ។ ឯយើងវិញក៏ខិតខំរៀនសូត្រពីគេវិញផង រកមើលឲ្យឃើញនូវចំណុចខ្លាំងរបស់គេដូចជាខាងស៊ូទ្រាំទ្រលំបាកវេទនា ស៊ីអត់ស៊ីឃ្លាន ហើយខិតខំបំពាក់ចំណុចខ្លាំងនេះឲ្យខ្លួនយើងដោយខិតខំកំចាត់និន្នាការ "អនុជន" របស់ខ្លួនឲ្យអស់ពី

[៨១] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៧៧

[៨២] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១២៣

ខ្លួនៗ ពិតមែនហើយ បញ្ហាជនបដិវត្តន៍ជាសម្ព័ន្ធមិត្តជាធម្មជាតិរបស់កសិករៗ ហើយនៅពេលដែលគេបានលត់ដំខ្លួនគេក្នុងការតស៊ូលំបាកវេទនាមិនខ្លាចស្លាប់រស់ គេអាចបោះបង់ចោលគោលជំហរវណ្ណៈដើមរបស់គេ ដើម្បីបំពាក់ខ្លួនគេនូវគោលជំហរវណ្ណៈកសិករវិញបានៗ ឯកសិករវិញ ក៏គេកសាងក្នុងចលនាតស៊ូបណ្ដើរ អប់រំរៀនសូត្រក្នុងចលនាទិទៀនស្វ័យទិទៀនបណ្ដើរៗ ពីទាបទៅខ្ពស់ គេជម្រុះចោលនូវគោលជំហរ "អនុជន" ជាប់នឹងស្រែមួយអំពកពីរអំពក ដើម្បីកសាង គោលជំហរ "វណ្ណៈអជន" ហានព្រយុទ្ធហានលះបង់ៗ

គេក៏បង្ហាត់ស្នូលទាំងនោះ ឲ្យចេះរួបរួមជាមួយសម្ព័ន្ធមិត្តផ្សេងទៀតទាំងអស់ ទោះបីគេជាសម្ព័ន្ធមិត្តបណ្ដោះអាសន្នក៏ដោយ ដើម្បីឯកោសត្រូវៗ នៅកម្ពុជាសត្រូវដែលសំខាន់ជាងគេពេលនោះ គឺសហរដ្ឋអាមេរិក ពីព្រោះសហរដ្ឋអាមេរិក ធ្វើសកម្មភាពបំផ្លាញនយោបាយឯករាជ្យអព្យាក្រិត្យរបស់ជាតិៗ ប៉ុន្តែមិនបានន័យថា គេត្រូវតែនៅជាប់ជាមួយសម្ព័ន្ធមិត្តនៅក្នុងវណសិប្បដែលគេជាវណ្ណៈផ្សេងនោះជារៀងរហូតទេ ពីព្រោះគេមានភារកិច្ចបន្តដឹកនាំបដិវត្តន៍ឈានទៅវាយរំលំរបបសក្តិភូមិ បំបាត់ចោលអយុត្តិធម៌សង្គម ហើយរៀបចំរបបសង្គមនិយមៗ

ឯផ្នែកខាងចាត់តាំងវិញ អង្គភាពជាមូលដ្ឋាន គឺសាខាដែលមានគ្នាត្រឹមតែបីទៅប្រាំមួយនាក់តែប៉ុណ្ណោះ "ដែលមានវិន័យដែក ដែលទាំងអស់គ្នាសុខចិត្តទទួលយកដោយស្ម័គចិត្ត" ហើយ "ត្រូវធ្វើការទិទៀន និងស្វ័យទិទៀនឲ្យជាប់ ដើម្បីពង្រឹងពង្រីកគោលជំហរវណ្ណៈអជនៗ (ដល់ថ្ងៃក្រោយពាក្យទាំងអស់នេះគេយកមកប្រើដើម្បីអប់រំខ្ញុំផងដែរៗ ហេតុនេះហើយបានជាខ្ញុំសុំអនុញ្ញាតយកពាក្យនេះមកប្រើក្នុងពេលនេះ ដើម្បីឲ្យឃើញបរិយាកាសនៅក្នុងចលនានៅពេលនោះ)ៗ ពីសាខាមួយទៅសាខាមួយ គេមិនឲ្យដឹងគ្នាទេៗ មានតែលេខាសាខាទេ ដែលស្គាល់អ្នកទទួលខុសត្រូវខាងលើផ្ទាល់របស់ខ្លួនៗ នៅក្នុងពេលប្រជុំសាខាម្ដងៗ គេមិនដែលភ្លេចគូសបញ្ជាក់ពីសារៈសំខាន់នៃលក្ខការណ៍សម្ងាត់ទេៗ អ្នកដឹកនាំទាំង៣នាក់មិនទៅប្រជុំសាខាជាមួយគេទេ តែមានសាខាមួយនៅកំពូលខាងលើសម្រាប់ពួកគាត់ដោយឡែកមានវិន័យដូចសាខាផ្សេងទៀតទាំងអស់ ដោយរួមទាំងការទិទៀនស្វ័យទិទៀនផងដែរៗ ក្រៅពីនេះក៏មានការប្រជុំក្របខ័ណ្ឌចង្អៀតនៅក្នុងផ្ទះដែលមានការធានាសន្តិសុខជាងគេ សម្រាប់អប់របំពាក់បំប៉ន់ស្នូលដែលរឹងមាំជាងគេឲ្យកាន់តែរឹងមាំថែមទៀតទាំងខាងមនោគមវិជ្ជា ទាំងខាងមាគ៌ានយោបាយ ទាំងខាងការចាត់តាំងៗ



គោលបំណងដើមរបស់គេ គឺប្រជុំសន្និបាតនៅឆ្នាំ១៩៦៨ ប៉ុន្តែវៀតណាមដែលខ្មែរនៅត្រូវការឲ្យគេយល់ស្របផងដែរ ក៏មានការយឺតយ៉ាវក្នុងការឆ្លើយតប ដោយគេសង្ស័យថាខ្មែរអាចរកវិធីគេចចេញពីគេៗ[៨៣] ប៉ុន្តែទីចុងបំផុតវៀតណាមក៏យល់ស្របថា រចនាសម្ព័ន្ធបច្ចុប្បន្ននេះ ដែលបែងចែកផ្នែកជនបទ និងផ្នែកទីក្រុងដោយឡែកពីគ្នាត្រូវតែផ្លាស់ប្ដូរ ហើយគេក៏យល់ស្របថាអាចធ្វើសន្និបាត បាននៅក្នុងរយៈពាក់កណ្ដាលទី២នៃឆ្នាំ១៩៥៩ៗ គឺនៅពេលនោះហើយដែលគេបានដំណឹងថា ស៊ីវ ហេង លេខាបក្សក្បត់មិនដឹងចាប់ពីពេលណាមកផងទេៗ ដូច្នេះបុព្វសិទ្ធ គឺយកវិធានការណ៍ដើម្បីការពារកុំឲ្យមានការខូចខាតធំពេកៗ អ្វីៗផ្សេងទៀតទាំងអស់ត្រូវទុកដោយឡែកសិនៗ

លោក ទូ សាមុទ នួន ជា សាឡុតស ហើយអ្នកទី៤ម្នាក់ទៀត ប្រហែលជាលោក សូភឹម ក៏បង្កើត "គណៈកម្មាធិការនៃកិច្ចការទូទៅ" មួយ ដើម្បីដឹកនាំចលនាទូទាំងប្រទេសទំរាំជ្រើសរើសបានអ្នកដឹកនាំថ្មីៗ ដូច្នេះហើយបានជាការវិវត្តន៍បណ្ដើរៗទៅ គណៈកម្មាធិការទីក្រុងក្លាយទៅជាគណៈកម្មាធិការមជ្ឈិម[៨៤]ៗ ការវិវត្តន៍នេះ រួមជាមួយ និង សមត្ថភាពរបស់លោក

[៨៣] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៣៥

[៨៤] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៣៥

សាឡុតស និងបញ្ញាជនចម្រើនផ្សេងទៀត ដែលទើបត្រឡប់មកពីស្រុកបារាំង ដែលចេះធ្វើឲ្យយុវជនសិស្ស ដែលមានដើមកំណើតផ្សេងៗពីគ្នានៅជនបទក៏ដូចទីក្រុង ភ្ញាក់រលឹកខាងនយោបាយបានជាកត្តាសំខាន់ដើម្បីធ្វើឲ្យឥទ្ធិពលរបស់គេកាន់តែឡើងនៅក្នុងបក្ស។ ដូច្នេះហើយបានជាលោកសាឡុតស បញ្ចូលលោក អៀង សារី និងវន វេត អ្នកទីក្រុងម្នាក់ទៀត ដែលគាត់បានស្គាល់នៅក្រៅឲ្យមកជួយការងារ ក្នុងគណៈកម្មាធិការទីក្រុងភ្នំពេញ។

### គ-មហាសន្និបាតឆ្នាំ៦០ ជំហានទី១ សំខាន់ឈានទៅរកមាគ៌ានយោបាយឯករាជមួយ

ទោះបីមានកាលំបាកលំបិនយ៉ាងណាក៏ដោយ គំរោងនៃលក្ខន្តិកៈ និងកម្មវិធីនយោបាយដែលបានរៀបចំដោយអ្នកដឹកនាំទាំងបីនាក់ ត្រូវបានផ្ញើទៅសាខាផ្សេងៗរបស់បក្សនៅដើមឆ្នាំ១៩៦០ ដោយមានទាំង "លក្ខណៈវិនិច្ឆ័យ ដើម្បីអាចចូលបក្សបានអមទៅជាមួយផង។"[៨៥] ពេលដែលខ្ញុំនិយាយលេងជាមួយអ្នកតស៊ូចាស់ៗគេថា លោកសាឡុតស ជាអ្នកដែលដើរតួសំខាន់ក្នុងការរៀបចំលក្ខន្តិកៈ និងកម្មវិធីនយោបាយ ប៉ុន្តែឥទ្ធិពលរបស់ លោកទូសាមុទ និងលោកនួន ជាក្នុងចំណោមកម្មាភិបាលកសិករចាស់ៗមានសារៈសំខាន់ណាស់ ដើម្បីប្រមូលបានកម្មាភិបាល ដូចជា សូ ភិម, កែវ មាស, រស់ ញឹម, កែ ពក និង ម៉ុក ជាដើម ហើយដើម្បីបក្សចាប់ឫសបានរហ័សនៅជនបទ។

បក្សថ្មីឈ្មោះ "បក្សពលករកម្ពុជា"។ តាមលោកអៀង សារី ប្រាប់លោកហ៊ីលីពហ្សរតថា ឈ្មោះនេះដឹងតែអ្នកដែលបានចូលរួមសន្និបាតទេ។ មិនមានកត់ត្រាក្នុងកម្មវិធីនយោបាយឬក្នុងលក្ខន្តិកៈទេ គ្រាន់តែមាននិយាយអំពីបក្សកម្ពុជាប៉ុណ្ណោះ។ ឯវៀតណាមវិញដឹងតែឈ្មោះចាស់ប៉ុណ្ណោះ គឺបក្ស

[៨៥] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៣៥



បដិវត្តិនៃប្រជាជនកម្ពុជា (បបបក)។ គេកំណត់ថាបក្សនេះជា បក្សរបស់ពលករ ដោយយកលទ្ធិម៉ាក្សនិនធ្វើជាមូលដ្ឋាន នៅជាប់ជិតស្និទ្ធជាមួយមហាជន មានការចាត់តាំងឈរលើមូលដ្ឋាននៃប្រជាធិបតេយ្យប្រមូលផ្តុំ ប្រើការទិទៀននឹងស្វ័យទិទៀនជាគោលការណ៍ដឹកនាំ។

សួរថា តើនរណាទៅជាវណ្ណៈពលករនោះ មិនសូវច្បាស់ទេ ប៉ុន្តែនៅក្នុងស្រុកមួយដែលជាប្រទេសកសិកម្មឱនថយ ដែលមិនមានវណ្ណៈអធនឧស្សាហកម្ម ពិបាករកពាក្យឲ្យច្បាស់ជាងនេះណាស់។ លោកសាឡុតស ដែលធ្លាប់អានសៀវភៅនៅប៉ារីស ក៏ដឹងហើយថា នៅចិនក៏គេមិនសូវតឹងរឹងលើពាក្យនេះដែរ ហើយនៅវៀតណាមក៏ដូច្នេះដែរ។

ឯការវិភាគវណ្ណៈនៅក្នុងសង្គមកម្ពុជា ក៏មិនមានអ្វីប្លែកខុសពីនៅចិនឬវៀតណាមដែរ។ ទិសដៅនៃកម្មវិធីនយោបាយ គឺធ្វើជាតួបនីយកម្មមធ្យោបាយផលិតកម្មទាំងអស់.... ដើម្បីសម្រេចផ្តាច់ការប្រជាធិបតេយ្យប្រជាជន ហើយឈានទៅកសាងរបបសង្គមនិយមឈរលើមូលដ្ឋាន នៃពាក្យស្លោក "ពីម្នាក់ៗតាមសមត្ថភាពរបស់ខ្លួន ឲ្យទៅម្នាក់ៗវិញតាមការងាររបស់ខ្លួន" "ក្រោមផ្តាច់ការរបស់ប្រជាជន" ដើម្បីតម្រង់ទិសទៅកុម្មុយនីស្ត"។

ក្នុងសំបុត្រមួយមកអ្នកដឹកនាំខ្មែរនៅចុងឆ្នាំ១៩៥៩ បក្សវៀតណាមបានរំលឹកឡើងវិញអំពីនយោបាយ ត្រូវគាំទ្ររបបសម្តេច សីហនុ ដែលគេបានលើកឡើង៤ឆ្នាំមកហើយ។ តាមវៀតណាមយល់ទស្សនៈរបស់គេនេះត្រូវបានរំលេចចេញនៅក្នុងគំនិត គ្រុតឆេហ្វ អំពី "ផ្លូវទៅសង្គមនិយមតាមសភា" ដែលមហាសន្និបាតលើកទី២០ របស់បក្សកុម្មុយនីស្តសូវៀតនៅមូស្គូបានលើកឡើង១ឆ្នាំក្រោយមក។

គោលគំនិតសំខាន់គឺ ក្នុងសម័យរួមរស់ជាមួយគ្នារវាងប្លុកទាំង២ បក្សកុម្មុយនីស្តអាចឈានទៅកាន់អំណាចបានតាមរយៈ ការបោះឆ្នោតមិនបាច់តស៊ូវណ្ណៈ និងប្រើហិង្សាបដិវត្តន៍ទេ។ ចំពោះលោកសាឡុតស ក្រោយពី

ពិសោធន៍នៃបក្សខ្មែរនៅឆ្នាំ១៩៥៤ និងឆ្នាំ១៩៥៨ លោកឃើញថា ពាក្យទាំងអស់នេះប្រហោងក្លួង។ ប៉ុន្តែសម្រាប់វៀតណាមវិញពាក្យទាំងអស់នេះជាអាវុធមួយមានប្រយោជន៍ណាស់ដើម្បីចាប់ខ្មែរឲ្យនៅស្ងៀម (ពីព្រោះបក្សខ្មែរដែលតូចមួយ ហេតុអ្វីក៏ហានអះអាងថា ចលនាកុម្មុយនីស្តសកលលោកខុសនោះ)។[៨៦] ចាប់តាំងពីឆ្នាំ១៩៥៦មក ស៊ីវ ហេង ដោយមានការលើកទឹកចិត្តពីវៀតណាមផង បានខិតខំពន្យល់ឲ្យសហការីរបស់គាត់ផ្តល់បុព្វសិទ្ធទៅការខិតខំរៀបចំបោះឆ្នោត មិនបាច់រៀបចំតស៊ូវណ្ណៈទេ។ ស៊ីវ ហេង បានអូសទាញកម្មាភិបាល ដែលធ្លាប់បានសហការជាមួយវៀតមិញបានច្រើនដែរក្នុងនេះរួមទាំលោកសូ ភីមផង។ ឯកម្មាភិបាលដែលមកពីស្រុកបារាំងមួយចំនួន ក៏លំអៀងទៅតាមនេះដែរ ដោយបានទទួលឥទ្ធិពលពីបក្សកុម្មុយនីស្តបារាំង។

នៅខែមករា ឆ្នាំ១៩៥៩ គណៈកម្មាធិការមជ្ឈឹមបក្សពលករវៀតណាមបានអនុញ្ញាតឲ្យចាប់ផ្តើមការតស៊ូអាវុធ នៅវៀតណាមខាងត្បូងឡើងវិញ "ដោយសំអាងហេតុផលថារដ្ឋាភិបាល ង៉ោ ឌិញឌៀម ជា "ឧបករណ៍របស់អាមេរិកសម្រាប់ឈ្លានពាន និងដាក់នឹមទាសភាព"។[៨៧] អ្នកនិពន្ធយោងទៅលោកឌុយរ៉ៀមឌុគ័រ "ផ្លូវពួកកុម្មុយនីស្តវៀតណាមទៅកាន់អំណាច"។ នៅចុងឆ្នាំ១៩៦០ ការបះបោរក្រោកឡើងតស៊ូ បានផ្ទុះឡើងនៅវៀតណាមខាងត្បូង ហើយពាក់កណ្តាលខែកញ្ញា មហាសន្និបាតលើកទី៣របស់បក្សពលករវៀតណាម ក៏យល់ស្របឲ្យធ្វើសង្គ្រាមឈ្លបទូទៅនៅវៀតណាមខាងត្បូង។ នៅពេលនោះដែរ ការតស៊ូអាវុធក៏ចាប់ផ្តើមឡើងវិញនៅលាវ។ ដូច្នេះខ្មែរពិបាកយល់ណាស់ ហេតុអ្វីបានជាមានតែខ្លួនគេដែលត្រូវអនុវត្តតាមទ្រឹស្តីមួយ ដែលពួកសម្ពន្ធមិត្តរបស់គេមិនព្រមគោរពផងនោះ។

[៨៦] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៣៦

[៨៧] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៣៦ (អ្នកនិពន្ធយោងទៅលើលោក ឌុយរ៉ៀមឌុគ័រ "ផ្លូវពួកកុម្មុយនិស្តវៀតណាមទៅកាន់អំណាច")



ពីរអាទិត្យក្រោយ ពីមហាសន្និបាតបក្សកុម្មុយនីស្តវៀតណាមត្រូវចប់ គណៈប្រតិភូ២១នាក់បានមកជួបជុំគ្នានៅផ្ទះលោក ឌិក សាគុណ ដែលជាសមាជិកផ្នែកខាងជើងម្នាក់នៃទីក្រុងភ្នំពេញរបស់លោកវន វេត (ហើយជាសមាជិកនៃវង់ម៉ាកស៊ីសកាលនៅស្រុកបារាំង) ដែលធ្វើការសំខាន់នៅខាងរទេះភ្លើងខ្មែរ ហើយនៅក្នុងវិទ្យាមួយនៅក្នុងរដ្ឋាការរទេះភ្លើង។ ដើម្បីជៀសវាងកុំឲ្យគេចាប់អារម្មណ៍ គណៈប្រតិភូទាំងនោះអញ្ជើញមកម្តងមួយៗ ឬតាមក្រុមតូចៗ ហើយលោកសា គុណ ដាក់មនុស្សឲ្យនៅចាំយាម ដើម្បីឲ្យសញ្ញានៅពេលដែលមានអ្នកក្រៅចូលមកជិត។ គេប្រជុំគ្នាអស់រយៈ៣ថ្ងៃ គឺពីថ្ងៃ៣០ កញ្ញា ដល់ថ្ងៃ២ តុលា។ គ្មានឯកសារអ្វីនៃការពិភាក្សានៅពេលនោះនៅសល់ទេ ហើយប្រហែលជាគេមិនបានរក្សាទុកផងទេ។

ប៉ុន្តែកម្មវិធី ដែលអង្គប្រជុំបានអនុមត័នោះជាជំហានមួយសំខាន់ណាស់ សំដៅទៅមាគ៌ាមួយឯករាជ្យ។ ៦ឆ្នាំក្រោយមកទៀត ក្រោយពីដំណើរមួយយ៉ាងវែង តែដោយព្យាយាមអំណត់បំផុត ដោយប្រុងប្រយ័ត្នជាប់ជានិច្ចកុំឲ្យវៀតណាមខឹង តែសំដៅជាប់ជានិច្ចទៅរកទិសឯករាជ្យពីវៀតណាម។ ដល់ផ្លូវបត់មួយដែលជៀសមិនផុត បក្សកម្ពុជាដើរតាមផ្លូវ ដែលបក្សវៀតណាមទទូចឲ្យដើរតាមតទៅទៀតលែងបានហើយ។ បើបន្តតាមការណែនាំនេះទៀតមានតែស្លាប់ខ្លួនឯង។ នៅពេលនោះទើបបក្សនេះយកឈ្មោះហៅថា "បក្សកុម្មុយនីស្តកម្ពុជា" (បកក)។ ន័យគឺជាការប្រកាសឯករាជ្យពីបក្សវៀតណាម។ ឈ្មោះនេះទៀត ក៏វៀណាមមិនទាន់ដឹងភ្លាមទេ។ ដល់ទៅពេលដែលសកម្មភាពរបស់គេលេចធ្លោឡើង ជាចលនាបដិវត្តន៍ជាតិមួយដោយឡែកច្បាស់ ទើបវៀតណាមដឹង។

### ឃ-អំពីមាគ៌ានយោបាយថ្មីរបស់បក្សថ្មី

មាគ៌ានេះកំណត់ថា "វណ្ណៈជិះជាន់" ជាសត្រូវសំខាន់ជាងគេនៃបដិវត្តន៍កម្ពុជា "ហើយ" ជាឧបករណ៍នៃចក្រព័ត្តិអាមេរិក"។ ដូច្នេះប្រជាជនកម្ពុជាត្រូវតែកំទេច "របបសក្តិភូមិ" តាមមធ្យោបាយសន្តិវិធី ឬតាមវិធីផ្សេងទៀត៖

"បដិវត្តិន៍កម្ពុជាត្រូវជ្រើសរើសរវាងរូបភាពតស៊ូ២យ៉ាង៖ គឺមធ្យោបាយសន្តិភាព ឬមធ្យោបាយមិនសន្តិភាព។ យើងនឹងខិតខំធ្វើអ្វីៗទាំងអស់ដែលអាចធ្វើទៅបាន ដើម្បីក្តាប់រូបភាពតស៊ូសន្តិភាពឲ្យជាប់ ពីព្រោះរូបភាពតស៊ូនេះមិនបណ្តាលឲ្យបាត់បង់អាយុជីវិតប្រជាជនច្រើនពេក។ ប៉ុន្តែយើងត្រូវត្រៀមគ្រប់ពេលវេលា ដើម្បីប្រើមធ្យោបាយមិនសន្តិភាព បើពួកចក្រពត្តិនិងពួកសក្តិភូមិ.....ចចេស រឹងរូស បង្ខំយើងឲ្យជ្រើសរើសយកវិធីនេះ....."។ បើពេលណាសត្រូវបដិវត្តន៍ បង្ខំយើងឲ្យចាប់យកអាវុធដោយខ្លួនយើង ជនបទនឹងផ្តល់ឲ្យយើងនូវលក្ខណៈ.....ល្អបំផុត។ អាស្រ័យហេតុនេះ បដិវត្តន៍ត្រូវប្រើលក្ខណៈសម្បត្តិដែលនៅកប់ ដើម្បីកសាងពង្រឹងនិងពង្រីកកម្លាំងនៅជនបទ...។ ជនបទជាមូលដ្ឋានសំខាន់សម្រាប់បដិវត្តន៍ ពីព្រោះនៅកម្ពុជាក៏ដូចនៅប្រទេសមិនទាន់រីកលូតលាស់ផ្សេងទៀត បដិវត្តន៍ជាតិ គឺជាបដិវត្តន៍កសិករ។ ទីក្រុងជា...ក្បាលម៉ាស៊ីនសម្រាប់វណ្ណៈកាន់អំណាច និងពួកចក្រពត្តិជាកន្លែងដែលសត្រូវបដិវត្តន៍ អាចប្រមូលកម្លាំងកំទេចយើង។"[៨៨]

ដោយគោលជំហរខ្មែរ បានត្រូវរៀបចំដោយប្រើពាក្យពេចន៍ប្រុងប្រយ័ត្នយ៉ាងនេះពួកកុម្មុយនីស្តវៀតណាមមិនដឹងធ្វើអ្វី ក្រៅពីឆ្លើយតបវិញតាមពាក្យពេចន៍ទន់ភ្លន់។ សាររបស់វៀតណាមមកអ្នកដឹកនាំកម្ពុជា ក្រោយមកមានតែសុំឲ្យអ្នកដឹកនាំកម្ពុជាអំណត់ ហើយសន្យាថា ក្រោយពីវៀតណាមខាងត្បូង និងលាវទទួលបានជ័យជម្នះ "បដិវត្តន៍កម្ពុជាក៏នឹងទទួលបានជ័យជម្នះផងដែរ"។[៨៩]

មានចំណុចខ្វែងគំនិតគ្នាច្រើនទៀត។ ឧទាហរណ៍ បក្សថ្មីមិននិយាយពីសាមគ្គីភាពឥណ្ឌូចិនទេ តែបែរជានិយាយថា "ខិតខំសម្រេចឲ្យបាន

[៨៨] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៣៧

[៨៩] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៣៨ (អ្នកនិពន្ធយោងទៅតាមកាសែតពាក់កណ្តាលផ្លូវការឈ្មោះ Réalités Cambodgiennes ចុះថ្ងៃទី ១៧ សីហា ១៩៦២។ តាមកាសែតនេះថាឈ្មោះអ្នកយកឯកសារនេះមកប្រគល់ឲ្យខាងភ្នំពេញ។)



ឯករាជ្យពេញលេញ កសាងសេដ្ឋកិច្ចជាតិមួយ ហើយស្ថាបនាជាតិកម្ពុជាមួយឯករាជ្យអធិបតេយ្យ និងសំបូររុងរឿង"។

សន្និបាតជ្រើសរើសក្រុមដឹកនាំថ្មី។ លោក ទូ សាមុទ ទៅជាលេខាបក្ស លោក នួន ជា ទៅជាអនុរបស់គាត់ ហើយលោកសាឡុតសជាអ្នកទី៣។ អ្នកទាំង៣នាក់ ជាសមាជិកពេញសិទ្ធនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិម។ លោកអៀង សារី លោក សូ ភឹម និងលោក ម៉ង់ ដែលពេលនោះជាលេខាភូមិភាគនារតី ជាសមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍ដោយមានសិទ្ធិចូលរួមជជែកពិភាក្សាក្នុងគណៈកម្មាធិការ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតទេ។

សន្និបាតឆ្នាំ១៩៦០ ជាសន្និបាតលើកទី១ ដែលពួកកុម្មុយនីស្តខ្មែរជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន ហើយកំណត់យុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់ខ្លួនដោយសេរី មិនមានអាណាព្យាបាលវៀតណាម។ ពីមុនមកការសម្រេចរបៀបនេះគឺ "គណៈកម្មាធិការការងារសម្រាប់កម្ពុជា" ដែលង្វៀង ថាញ់ សឺងធ្វើជាប្រធានជាអ្នកសម្រេចជួស។[៩០] លើកនេះ មិនគ្រាន់តែគ្មានប្រតិភូនៃបក្សវៀតណាមម្នាក់មកចូលរួមនោះទេ ប៉ុន្តែកម្មវិធីរបស់បក្ស -ពិតមែនតែសរសេរដោយគិតគូរប្រយ័ត្នប្រយែងដល់ប្រតិកម្មរបស់ហាណូយ -តែមិនបានទៅសុំការយល់ស្របពីហាណូយមុនទេ។

ដើម្បីគូសបញ្ជាក់នូវការចេញដំណើរថ្មី សមាជិកទាំងអស់នៃចលនាត្រូវធ្វើពាក្យសុំចូលបក្សសារជាថ្មីឡើងវិញ។[៩១]

ក្រោយពីការប្រជុំមហាសន្និបាត ហើយទាំងអស់គ្នាហាក់ដូចជាមានថាមពលថ្មី ហើយប្រញាប់ប្រញាល់ចេញទៅកន្លែងរបស់គេវិញ ដើម្បី

[៩០] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៣៩

[៩១] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៣៩

ខិតខំកសាងមូលដ្ឋាននៅជនបទ ដែលជាកូនសោសម្រាប់អនាគតនៃបក្ស បើប្រសិនជា ដូចជាការិយាល័យអចិន្ត្រៃយ៍បានលើកឡើងច្បាស់ហើយ មធ្យោបាយសន្តិវិធី "មិនបានផល"។ ម៉ង់ និងប្រាសិទ្ធ ត្រឡប់ទៅនិរតីវិញ ភ្លាម។ រស់ញឹម បោះបង់ចោលស្រែរបស់គាត់នៅខាងត្បូងបាត់ដំបង ដើម្បីទៅរៀបចំបណ្ដាញនៃពួកអតីតឥស្សរៈនៅជុំវិញសំឡូតឡើងវិញ។ សូ ភឹម ត្រឡប់ទៅភូមិភាគបូព៌ាវិញ។"

ង-ការខិតខំរៀនសូត្រពីកិច្ចព្រមព្រៀងហ្សឺណែវ ពង្រឹងគោលជំហរឯករាជម្ចាស់ការខ្លួនទីពឹងខ្លួន

ក្នុងការនិយាយលេងជាមួយពួកម្មាភិបាលថ្នាក់កណ្ដាល និងថ្នាក់ក្រោម ខ្ញុំមិនដែលឮគេនិយាយអំពីសំបុត្រ អ្នកដឹកនាំវៀតណាមសោះ ហើយក៏មិនដែលឮគេនិយាយពីមហាសន្និបាតលើកទី២០ នៃបក្សកុម្មុយនីស្តសូវៀតសោះទេ ព្រមទាំងមិនដែលឮគេនិយាយពីការត្រូវជ្រើសរើសរវាងមធ្យោបាយសន្តិវិធីឬមិនសន្តិវិធីទេ។ ខ្ញុំឮគេនិយាយតែពីរឿងខិតខំរៀនសូត្រដកពិសោធន៍ពីកិច្ចព្រមព្រៀងហ្សឺណែវជាសំខាន់។ ក្នុងការរៀនសូត្រនេះ គេខំតែគូសសង្កត់ឲ្យកម្មាភិបាលឃើញថា ទីចុងបំផុតក្នុងពេលសន្និសិទ្ធហ្សឺណែវ ក៏ដូចក្នុងពេលក្រោយមកទៀត វៀតណាមមិនអាចជួយការពារផលប្រយោជន៍កម្ពុជាបានទេ។ ដូច្នេះពឹងផ្អែកលើ "អន្តរជាតិនិយមវណ្ណៈអធន" ដែលវៀតណាមតែងនិយាយមិនដាច់ពីមាត់នោះមិនបានទេ។ មេរៀនសំខាន់បំផុតសម្រាប់គេ គឺពិសោធន៍របស់គេក្រោយឆ្នាំ១៩៥៤ និងក្នុងពេលបោះឆ្នោតឆ្នាំ១៩៥៥ ដែលគេត្រូវគេដេញចាប់ ដេញព័ទ្ធ ដេញបាញ់ ដូចសត្វឈ្លូស ឯខ្លួនគេវិញពួនតែក្នុងព្រៃមិនទាំងហានអើតក្បាលចូលភូមិផង។ ពិសោធន៍ទាំងអស់នេះគេត្រូវចងចាំជាពិសោធន៍ប្រចាំជីវិត ដើម្បីគេក្ដាប់វាសនារបស់គេឲ្យជាប់នៅនឹងដៃគេ ហើយឈប់អនុញ្ញាតឲ្យប្រទេសណាទាំងអស់ចាត់ចែងជំនួសគេ។ គេត្រូវឈរលើគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនពឹងលើកម្លាំងរបស់ខ្លួនទ្រាំទ្រការលំបាកវេទនាស្លាប់រស់ដោយខ្លួនគេ។ គេត្រូវតែបន្ត



រក្សាសាមគ្គីជាមួយបក្សវៀតណាម ដែលកំពុងបន្តដឹកនាំចលនាតស៊ូដើម្បីបង្រួបបង្រួមប្រទេសវៀតណាម តែគេជាសមាជិកបក្សមួយឯករាជ្យមិននៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនទៀតទេ។

គោលការណ៍កសាងបក្សនៅជនបទក៏ដូចនៅទីក្រុង គឺកសាងក្នុងចលនាតស៊ូ។ នៅទីក្រុងពាក្យស្លោក គឺតស៊ូជាតិ និងប្រជាធិបតេយ្យ។ នៅជនបទពាក្យស្លោកគឺតស៊ូដើម្បីកែប្រែជីវភាព និងប្រឆាំងការរំលោភបំពានគ្រប់បែបយ៉ាង។

គេខិតខំបំផុស និងហ្វឹកហាត់ឲ្យកសិករចេះតស៊ូការពារផលប្រយោជន៍សេដ្ឋកិច្ចជីវភាពរបស់គេដោយខ្លួនគេ ពីទាបទៅខ្ពស់ ចេះរៀបចំចាត់តាំងកម្លាំងរបស់គេតាមរូបភាពជាសមាគមផ្សេងៗជាច្រើនរូបភាព៖ សមាគមស្រូវ សមាគមថ្នាំពេទ្យ សមាគមប្រេងកាត រួមគ្នាទិញអ្វីដែលគេត្រូវការយកមកលក់ដោយមិនយកចំណេញច្រើនពេក ដើម្បីទប់ទល់ឈ្មួញស្ពានកណ្ដាល... សាមគ្គីគ្នាតស៊ូប្រឆាំងនឹងអំពើប្លន់ដី និងការរំលោភគ្រប់បែប គ្រប់យ៉ាងពីសំណាក់ពួកកាន់អំណាច។ មេឃុំណា ជំទប់ណា មេព្រៃណា ក្រសួងនេសាទណា ដែលឃោរឃៅជាងគេ គេនាំគ្នាចាប់យកទៅសម្លាប់ចោល...។ ហើយគេតស៊ូការពារគ្នាទៅវិញទៅមកប្រឆាំងការរាតត្បាត ចាប់ចង និងជួយលាក់បំពួនគ្នាកុំឲ្យពួកកាន់អំណាចចាប់បាន...។ល។ គេមានរហូតដល់ចាត់តាំងជា "កងការពារសម្ងាត់" ដែលប្រើតែក្រមា ខ្សែគោ កាំបិត ពូថៅ ដំបងជាអាវុធ ចាប់អ្នកណាដែលហានលួចចូលមកក្នុងភូមិ លួចស្ដាប់ការប្រជុំរបស់កសិករ ឬការប្រជុំរបស់កម្មាភិបាល។ (ដល់ដើមឆ្នាំ១៩៦៨ "កងការពារសម្ងាត់" ទាំងនោះហើយ ដែលដើរតួឈានមុខនាំអ្នកភូមិទៅហ៊ុមព័ទ្ធបន្ទាយរបស់លោក លន់ នល់ រឹបយកអាវុធដោយមិនឲ្យទាហានដឹងខ្លួនមុន)។ សកម្មភាពជំសំបូរបែបទាំងអស់នេះហើយ ដែលបានជួយឲ្យកសិករឃើញកម្លាំងរបស់ខ្លួនកាន់តែច្បាស់ ហើយកាន់តែភ្ញាក់រលឹកខាងនយោបាយ។ បណ្ដើរៗទៅគេក៏ចេះពិគ្រោះគ្នាដោះស្រាយបញ្ហាផ្សេងៗ ក្នុងភូមិទាំងអស់ ដោយខ្លួនគេ

ហើយភូមិក៏របូតចេញពីការត្រួតត្រារបស់ផ្ដេអំណាចភូមិឃុំ ដើម្បីក្លាយទៅជាក្រឡាមួយនៃសំណាញ់បដិវត្តន៍នៅជនបទ ដែលចេះតែត្បាញបន្តទៅទៀតយ៉ាងនេះរាល់ថ្ងៃ។ គឺតាមរបៀបនេះហើយ ដែលកសិកររៀនសូត្រអំពីខ្លួនទីពឹងខ្លួន អំពី "ខ្លួនធ្វើជាម្ចាស់លើវាសនារបស់ខ្លួន" និងអំពីអត្ថន័យយ៉ាងជ្រាលជ្រៅនៃពាក្យថា "ឯករាជ្យម្ចាស់ការ"។ និយាយមួយម៉ាត់ គឺយ៉ាងនេះហើយ ដែលគេរៀនសូត្រពីពិសោធន៍នៃកិច្ចព្រមព្រៀងហ្សឺណែវ។

ព្រមជាមួយនេះនៅពេលគេប្រជុំគ្នាម្ដងៗ ក៏មានរបៀបវារៈមួយហៅថា សភាពការណ៍រួមៗ គឺតាមរបៀបវារៈនេះហើយ ដែលគេបានយល់ដឹងពីសភាពការណ៍ទូទាំងប្រទេស អំពីការរាតត្បាតចាប់ចងនៅខេត្តនេះ ឬខេត្តនោះ អំពីសហរដ្ឋអាមេរិក និងអង្គការសេអាតូកៀបសង្កត់កម្ពុជា អំពីការវិវត្តនៃសង្គ្រាមនៅវៀតណាម អំពីលន់នល់ត្រៀមរៀបចំធ្វើរដ្ឋប្រហារ។ល។

### ប-ឆ្នាំ១៩៦៣ ៖ ផ្លូវបត់សំខាន់ទី២

សន្ទុះកថាប្រឆាំងកុម្មុយនីស្ដខ្លាំងជាងគេរបស់សម្ដេចនរោត្ដម សីហនុ គឺនៅពេលបោះឆ្នោតឆ្នាំ១៩៥៨។ ហើយក៏ចុះថយទៅវិញនៅឆ្នាំ១៩៥៩ ដោយសម្ដេចជាប់រវល់អំពីការ ដែលកងទ័ពវៀតណាមខាងត្បូងចូលលុកលុយជ្រៅមកក្នុងដីកម្ពុជា ហើយប្រទេសថៃ វៀតណាមខាងត្បូង និងសហរដ្ឋអាមេរិកឃុបឃិតគ្នាបង្កើតរឿងក្បត់ដាប ឈួន ដោយគេមិនសប្បាយចិត្តអំពីថា សម្ដេច "លំអៀងទៅខាងកុម្មុយនីស្ដ"។ ហើយសម្ដេចក៏ខ្វាល់អំពីប្រទេសទាំង៣ គាំទ្រសឹង ង៉ុកថាញ់។ នេះហើយដែលនាំឲ្យសម្ដេចខិតទៅជិតខាងប្រទេសនៃប្លុកសង្គមនិយម។ នៅក្នុងប្រទេសពេញមួយឆ្នាំ១៩៦០ សកម្មភាព "ខាងឆ្វេង" ក្នុងនេះមានទាំងក្រុមប្រជាជនផង ក៏ត្រូវបានសណ្ដោស។ ប៉ុន្តែនយោបាយនេះក៏អាស្រ័យលើការពេញប្រទ័យ ឬមិនពេញប្រទ័យរបស់ព្រះអង្គដែលចេះតែផ្លាស់ប្ដូរញឹកញាប់ និងការដែលព្រះអង្គរុញពួកឆ្វេងឲ្យជល់ពួកស្ដាំ ហើយរុញពួកស្ដាំឲ្យជល់ពួកឆ្វេង។ ដូច្នេះ



កម្លាំងដែលស្និទ្ធជាមួយអាមេរិក ក៏ចេះតែពង្រឹង និងពង្រីក ហើយការរាតត្បាតប្រឆាំងនឹងពួកឆ្វេង តែងមានចុះមានឡើង តែនិយាយរួមគឺឡើង។

ដូច្នេះហើយបានជានៅថ្ងៃ១០ មករា ឆ្នាំ១៩៦២ សមាជិកក្រុមប្រជាជន ១៤នាក់ ត្រូវបានចាប់នៅខេត្តកំពង់ចាម។ ភាគច្រើនអ្នកដែលត្រូវចាប់ទាំងនោះ គឺជាអ្នកភូមិស្រុកនោះ។ ប៉ូលីសនិយាយថា អ្នកទាំងនោះឆ្លើយថា គេធ្វើការក្រោមបង្គាប់របស់លោកនន សួន ដើម្បីប្រមូលការសម្ងាត់ខាងនយោបាយ និងយោធាក្នុងតំបន់។ ដូច្នេះនន សួន និងអ្នកទាំងអស់គ្នា ក៏ត្រូវចោទថា បានឃុបឃិតគ្នាប្រឆាំងនឹងរដ្ឋ។ លោកបែន គៀរណាន់យល់ថា ការចោទប្រកាន់នេះវាផ្ទុយគ្នា។[៩២] គាត់កត់សម្គាល់ថា មួយផ្នែកអ្នកទាំងនោះត្រូវគេចោទថា ជាផ្នែកមួយនៃបណ្ដាញស៊ើបការ ដើម្បីប្រមូលដំណឹងពីប៉ុស្ដិ៍យោធានៅតាមព្រំដែន មួយផ្នែកទៀត កាសែតពាក់កណ្ដាលផ្លូវការ Réalités Cambodgiennes បានសរសេរអំពីរឿងនេះថា "ក្នុងការដាក់ស្នែងនៅពេលមុនបោះឆ្នោត (ដែលត្រូវធ្វើនៅខែមិថុនា) ក្រុមប្រជាជនខំបង្កើនការឃោសនាប្រកបដោយការពិសពុលរបស់គេ ដើម្បីបង្កើនភ័ព្វសំណាងរបស់គេ និងដើម្បីបំពេញចិត្តចៅហ្វាយនាយបរទេសរបស់គេ"។ ថ្ងៃ២១ មករា វិចារណកថាមួយរបស់កាសែតប្រជាជន ចោទរដ្ឋមន្ត្រីខាងសន្តិសុខជាតិថា "បានធ្វើសកម្មភាពគ្រប់បែបយ៉ាង ដើម្បីឲ្យកាសែតគេជួបនឹងការលំបាក"។ ដោយកាសែតនេះមានរឿងរ៉ាវជាប់ជាមួយនឹងប៉ូលីស ដោយសារតែអត្ថបទរបស់គេទិតៀនរដ្ឋាភិបាល ដូច្នេះវិចារណកថានេះក៏ក្លាយទៅជារឿងមួយទៀតនាំឲ្យជូ ជេត និងសហការីរបស់គាត់ម្នាក់ទៀតត្រូវចាប់ ហើយកាសែតក៏ត្រូវបិទ។ ដូច្នេះការខិតខំរបស់ពួកកុម្មុយនីស្ដជាលើកទី១ និងជាលើកចុងក្រោយបង្អស់ ដើម្បីធ្វើសកម្មភាពស្របច្បាប់ត្រូវចប់។ តាមការណែនាំរបស់សម្ដេច តុលាការយោធាក៏កាត់ទោសប្រហារជីវិត នន សួន និងសហការីរបស់គាត់។ នៅពេលបោះ

---

[៩២] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៩៥

ឆ្នោតឆ្នាំ១៩៦២ ក្រុមប្រជាជនអត់មានបេក្ខជនទៀតទេ ហើយក៏ឈប់បាត់រហូតទៅ ប៉ុន្តែក្រុម "ខាងឆ្វេង" នៅមាននៅក្នុងសភានៅឡើយ។ លោក ហ៊ូ យន់ ដែលលោកនិយាយមិនចេះប្រណីមាត់ និងហ៊ុយ នឹម ចាងហ្វាងគយ ក៏ត្រូវជាប់ឆ្នោតឡើងវិញ។ ឯផ្ទាល់ខ្លួនខ្ញុំក៏ជាប់ជាសមាជិកសភាជាលើកដំបូង ហើយក៏ត្រូវបានចូលក្នុងរដ្ឋាភិបាលថែមទៀត។

នៅខែកក្កដា ក៏មានកើតរឿងមួយទៀត។ លេខាបក្សកុម្មុយនីស្ត គឺលោក ទូ សាមុទ ត្រូវបានគេចាប់ និងសម្លាប់។[៥៣] គាត់រស់នៅឯទួលស្វាយព្រៃខាងនីរតីទីក្រុងភ្នំពេញ។ ថ្ងៃនោះគាត់ក៏ចេញពីផ្ទះគាត់ដើម្បីទិញថ្នាំឲ្យកូនគាត់ឈឺ ប៉ូលិសសម្ងាត់នៅរង់ចាំគាត់។ តាមឮគេនិយាយគេថា គាត់បានត្រូវនាំទៅផ្ទះមួយរបស់លោក លន់ នល់ ដើម្បីធ្វើទារុណកម្ម ប៉ុន្តែគាត់មិនព្រមនិយាយ ដូច្នេះគាត់ក៏ត្រូវស្លាប់ ហើយគេយកទៅកប់នៅខាងត្បូងស្ទឹងមានជ័យ។

គេមិនអាចដឹងបានទេ តើនរណាដែលជាអ្នកក្បត់គាត់។ ពិតមែនហើយ មរណៈភាពរបស់គាត់បានបើកទ្វារឲ្យលោក ប៉ុល ពត ឡើងមកធ្វើជាអ្នកដឹកនាំផ្លូវការរបស់បក្ស។ ការពិតដូចមានរៀបរាប់ពីខាងលើ ហើយឥទ្ធិពលរបស់លោក ប៉ុល ពត ចេះតែកើនឡើងជាប់ជានិច្ចទាំងនៅខាងលើទាំងនៅទូទាំងបក្ស។

យើងទាំងអស់គ្នាបានដឹងហើយថា លោកទូ សាមុទ បានរង់ចាំរហូតដល់បោះឆ្នោតឆ្នាំ១៩៥៥ចប់សព្វគ្រប់ ទើបគាត់លបលួចចូលមកទីក្រុងភ្នំពេញ ត្រៀមចាប់ផ្តើមសកម្មភាពក្នុងឋានៈជាអ្នកទទួលខុសត្រូវការងារទីក្រុង។ ចំណែកឯលោកសាឡុតសវិញ គាត់បានចាប់ផ្តើមបង្ហាញនូវសមត្ថភាពនយោបាយរបស់គាត់ជាបណ្តើរៗមកហើយ ក្នុងការរៀបចំកម្លាំងដើម្បីទាមទារឲ្យកម្ពុជាដើរតាមនយោបាយអព្យាក្រិត មិនចូលបក្សសម្ព័ន្ធ

[៥៣] ហ៊ីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៤១, បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៥៧



ក្នុងឱកាសការបោះឆ្នោតឆ្នាំ១៩៥៥។ លើចំណុចនេះសូមអានលោក បែន គៀរណាន់ដូចតទៅ: "ពិតមែនតែពីមុនមកគាត់មិនមែនជាអ្នកដឹកនាំបដិវត្តន៍ក៏ដោយ ការអប់រំរបស់គាត់ ហើយការដែលភ្នំពេញដូចជាផ្ទះគាត់ទៅហើយ លោកប៉ុលពតបានចាប់ផ្តើមមានទម្ងន់នយោបាយបណ្តើរៗទៅហើយ នៅពេលដែលអ្នកដឹកនាំចលនាតស៊ូពីមុនមក (ដែលទាំងអស់គ្នាសុទ្ធតែចេញមកពីក្រុមគ្រួសារថ្នាក់ទាបនៅជនបទ) កំពុងតែស្ទាបៗរកផ្លូវមួយ ដែលគេមិនដែលធ្លាប់ស្គាល់ទាល់តែសោះ"។[៥៤] តាំងពីពេលនោះមកប៉ុលពត តែងតែបានបង្ហាញនូវសមត្ថភាពវិភាគរបស់គាត់ ហើយពេលណាក៏លោកតា និងលោកនួន ជា ទទួលយកការវិភាគរបស់គាត់។ ហេតុនេះបានជាបន្តិចម្តងៗ ពិសេសចាប់តាំងពីមហាសន្និបាទឆ្នាំ១៩៦០ម៉្លេះ ប៉ុលពតដើរតួជាលេខាបក្សស្រេចទៅហើយ ទោះបីជាផ្លូវការ គាត់ជាអ្នកទី៣ក៏ដោយ។

យើងនៅចាំបានហើយថាតាំងពីឆ្នាំ១៩៥៧ម៉្លេះ អ្នកដឹកនាំទាំងបីនាក់បានយល់ស្របគ្នាហើយ លើគោលការណ៍បង្កើតបក្សខ្មែរមួយថ្មី ដែលនៅជាសម្ព័ន្ធមិត្តជាមួយវៀតណាម តែមិននៅក្រោមការបង្គាប់របស់វៀតណាមទៀតទេ។ ហើយប៉ុលពត បានដើរតួនាទីសំខាន់ក្នុងការរៀបចំកម្មវិធីនយោបាយនិងលក្ខន្តិកៈ។ ដូច្នេះគេមិនឃើញថា ប៉ុលពត មានផលប្រយោជន៍អ្វីនឹងទៅសម្លាប់លោកទូសាមុទ្ទទេ។ ម៉្យាងទៀតនៅក្នុងសេចក្តីសារភាពរបស់គាត់នៅឆ្នាំ១៩៧៦លោក វន វេត បានសរសេរថា "ពេលគេចាប់លោកតាទូ...បង។ (អ្នកដឹកនាំបក្ស) ឈប់ចេញហើយឈប់ធ្វើការងារចំហរ"។[៥៥] លោកវន វេតប្រើពាក្យថា "លោកតាទូ" មានន័យថា អ្នកទាំងអស់គ្នានៅគោរពគាត់រហូតមក។ ទោះបីយ៉ាងនេះក៏ដោយ តាំងពីឆ្នាំ១៩៧៩មក វៀតណាមនៅតែថា ទូ សាមុទ បានត្រូវគេសម្លាប់ដោយមានការឃុបឃិតពីប៉ុលពត។ នៅ

[៥៤] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៥៧

[៥៥] ដេវិត ឆាន់ឡែរ "បងធំទីមួយ" ទំព័រ៦១

ចុងខែកុម្ភៈ ឆ្នាំ១៩៦៣ មហាសន្និបាតលើកទី២ក៏បានកោះប្រជុំ ដើម្បីប្រថាប់ត្រាលោកសាឡុតស ជាលេខាបក្សៗ[៩៦] នួន ជា នៅជាអ្នកទី២ដដែល អៀង សារី និងសូ ភឹម ទៅជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍។ សមាជិកមជ្ឈឹម៤នាក់ទៀតត្រូវជ្រើសរើសបន្ថែម គឺម៉ុក ដែលជាអនុរបស់តាម៉ង់នៅនីរតី រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យ វន វេត ដែលជាគណៈកម្មាធិការភ្នំពេញ ហើយទីចុងបំផុតគឺ សុន សេន ។

ការប្រជុំនេះតែមួយថ្ងៃទេ ហើយមានមនុស្សចូលរួមតែ ១៧ ឬ១៨នាក់ទេ។ ប៉ុន្តែមហាសន្និបាតបានរៀបចំក្បាលម៉ាស៊ីនដឹកនាំឡើងវិញនោះបានទាន់ពេល។

ចំពោះអ្នកខាងលិច ដើមឆ្នាំ១៩៦០ គឺជាឆ្នាំដែលសុខសាន្ត និងសម្បូរសប្បាយជាងគេនៅកម្ពុជា។ ប៉ុន្តែរលកបាតសមុទ្រ កំពុងចាប់ផ្តើមបោកបក់ខ្លាំងហើយ។ ការដែលរដ្ឋអំណាចចេះតែរំលោភច្បាប់ ពេលខ្លះដោយមានសម្តេចស៊ុមគ្រលំជាមួយផង កាន់តែធ្វើឲ្យគេលែងទទួលបានហើយ។

"ចំពោះយុវជនខ្មែរកាន់តែច្រើនឡើង សម្តេច សីហនុ មិនមែនជាមនុស្សសម្រាប់ដោះស្រាយបញ្ហាស្រុកទេសទេ គឺជាមនុស្សដែលបង្កើតបញ្ហា គឺជានិមិត្តរូបនៃរបបមួយដែលហួសសម័យ ដែលតំណែងនាទីក្នុងរដ្ឋជាវត្ថុសម្រាប់លក់ និងសម្រាប់ទិញ គឺជារបបសក្តិភូមិ ដែលបាននាំមកនូវរូបភាពនៃសម័យទំនើប តែគ្មានអ្វីជាខ្លឹមសារទេ"។ ពាក្យនេះ របស់លោកហ្វីលីពហ្សរត បានលាតត្រដាងការគិតគូររបស់យុវជនពេលនោះហើយ។[៩៧] និសិត្សត្រូវការរដ្ឋាភិបាលមួយ សមរម្យ គិតគូរ ដល់យុត្តិធម៌សង្គម គឺត្រូវការឲ្យមានការផ្លាស់ប្តូរ។ នៅសៀមរាប ការតវ៉ាដ៏តូចមួយរបស់និសិត្សប្រឆាំងនឹងប៉ូលីសដែលចេះតែបង្កៀងជាមួយគេ បានក្លាយទៅជាការបះបោរមួយ នៅពេល

---

[៩៦] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៤១

[៩៧] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៣៥



ដែលគេដឹងថា មាននិសិត្សម្នាក់បានស្លាប់នៅពេលដែលកំពុងជាប់ឃុំក្នុងប៉ុស្តិ៍ប៉ូលីស។[៩៨] ដើម្បីសងសឹកវិញ និសិត្សបានចោមគ្នាវាយមេប៉ូលីស២នាក់ទាល់តែស្លាប់។ ប៉ុស្តិ៍ប៉ូលីស ត្រូវនិសិត្សវាយកំទេច ការិយាល័យ តុ ទូ កៅអីត្រូវរើសចេញមកក្រៅ ហើយដុតចោល។ អស់រយៈ៣ថ្ងៃ គឺពីថ្ងៃ២៤-២៦ កុម្ភៈ សៀមរាប ត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សិស្ស។ បដារបស់គេសរសេរថា "សង្គមពុករលួយ" "សង្គមអយុត្តិធម៌"។ រដ្ឋមន្ត្រីសិក្សាធិការ ម្នីម្នាទៅរកចរចាជាមួយសិស្ស។ ប៉ុន្តែខ្លួនលោក និងមន្ត្រីផ្សេងៗដែលហែរហមលោកត្រូវសិស្សចាប់ ហើយបណ្តើរអាគ្រោះឲ្យអ្នកឈរមើលតាមផ្លូវស្រែកហូរកញ្ជ្រៀវ។ បាតុកម្មប្រហាក់ប្រហែលគ្នានេះ ក៏មាននៅភ្នំពេញ និងកំពង់ចាមទៀត។[៩៩]

សម្តេចនរោត្តម សីហនុ ពេលនោះកំពុងធ្វើទស្សនកិច្ចនៅចិន។ ពេលលោកបានទទួលដំណឹងបាតុកម្ម ទាំងអស់នោះ លោកខ្ញាល់ខ្លាំង ហើយផ្ញើទូរលេខមួយណែនាំឲ្យស៊ើបអង្កេត។ លន់ នល់ យល់ថាការណែនាំនេះជាការអនុញ្ញាតឲ្យរាតត្បាត ចំពោះអ្នកដែលគេយល់ថាជាកុម្មុយនីស្ត។ ពេលសម្តេចយាងត្រឡប់មកវិញនៅដើមខែមីនា ព្រះអង្គក៏បន្ទោសនាយករដ្ឋមន្ត្រី គឺសម្តេចនរោត្តម កន្តុល ថា "គ្មានសមត្ថភាព" ទាមទារឲ្យរដ្ឋាភិបាលលាឈប់ ប្រកាសរំលាយសង្គម និងសភា ហើយឲ្យមានការបោះឆ្នោតថ្មី។ ថ្ងៃ៤មីនា នៅពេលដែលការតឹងតែងខាងនយោបាយឡើងដល់កំពូល ព្រះអង្គក៏ផ្សាយបញ្ជីអ្នកទាំង៣៤នាក់ ដែលលន់នល់បានរៀបចំ ហើយចោទពួកទាំង៣៤នាក់នេះថា "កំសាក លាក់ពុទ្ធ បំផ្លិចបំផ្លាញ វិទ្ធង្សណា ក្បត់ជាតិ" ហើយបានឲ្យគេមករៀបចំរដ្ឋាភិបាលមួយ ដើម្បីបង្ហាញប្រជាជនថាតើគេមានសមត្ថភាពដល់ត្រឹមណា (តែព្រះអង្គខ្លួនលោកក៏រក្សាសិទ្ធិ ដើម្បីចាត់តាំងរដ្ឋមន្ត្រីខាងប៉ូលីស មហាផ្ទៃ និងការពារប្រទេស)។

---

[៩៨] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៤២-១៤៣, ដេវិត ឆាន់ឡែរ "បងធំទីមួយ" ទំព័រ៦៣-៦៤, បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៩៩-២០២

[៩៩] ដេវិត ឆាន់ឡែរ "បងធំទីមួយ" ទំព័រ៦៣, ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៤៣

ថ្ងៃ៧ មីនា លោកក៏កោះហៅក្រុមនោះទាំងមូល ឲ្យមកជួបជុំគ្នានៅទីស្តីការនាយករដ្ឋមន្ត្រី ឲ្យម្នាក់ៗឆ្លើយដោយលាយល័ក្ខអក្សរថា តើគេសុខចិត្តចាត់តាំងរដ្ឋាភិបាលឬមិនសុខចិត្ត។ ទាំងអស់គ្នាក៏សរសេរឆ្លើយថា មានតែសម្តេចទេ ដែលមានសមត្ថភាពដឹកនាំប្រទេស។

ប៉ុន្តែក្នុងចំណោមអ្នក៣៤នាក់ មាន២នាក់ដែលមិនឃើញចេញមុខ គឺលោក ជូជេត ដែលទើបតែរួចពីគុក៣អាទិត្យមុននេះហើយ បានរត់ចូលព្រៃមុនស្រេច និងលោក សាឡុតស ដែលរត់ពួនតាំងពីពេលផ្សាយបញ្ជីថ្ងៃដំបូងម៉្លេះ។[១០០] ដល់ពាក់កណ្តាលខែមីនាព្យុះសង្ឃរាក៏ស្ងាត់ទៅវិញ ការស្រែកស្តីបន្ទោសរបស់សម្តេចលើសភា រដ្ឋាភិបាល និងសង្គម ត្រូវបំភ្លេចចោលដោយស្ងាត់ៗ។ ប៉ុន្តែនៅក្នុងការច្រឡោតរបស់សម្តេច ដូចជាមានអ្វីមួយដែលសម្តេចបានគិតគូរហ្មត់ចត់។ គឺក្រោយពីបានគង់នៅ៣អាទិត្យនៅចិន ច្រៀងសរសើររដ្ឋកុម្មុយនីស្តមួយនេះ ព្រះអង្គមានបំណងព្រមានថា កម្ពុជាជារបស់ព្រះអង្គ។

នៅក្នុងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា លោក សាឡុតស ក៏ប្រកាសថា សមាជិកគណៈអចិន្ត្រៃយ៍ទាំង៣នាក់ ដែលមានឈ្មោះនៅក្នុងបញ្ជី ត្រូវតែចាកចេញពីភ្នំពេញ។[១០១] ម្យ៉ាងទៀតគំនិតនេះមានជាពន្ទុកតាំងពីឆ្នាំ១៩៦០មកហើយ។ ថ្ងៃក្រោយមកលោក អៀង សារី បានប្រាប់លោក ហ្វីលីព ហ្សរតថា គាត់បានប្រឆាំងនឹងគំនិតនេះ។ គាត់យល់ថាមុននឹងចេញពីទីក្រុងភ្នំពេញ បក្សត្រូវមានមូលដ្ឋានរបស់ខ្លួននៅជនបទសិន ហើយត្រូវមានបណ្តាញនៅក្នុងទីក្រុងឲ្យរឹងមាំ។ ប៉ុន្តែលោកនួន ជា ដែលគាត់អត់មានឈ្មោះនៅក្នុងបញ្ជី៣៤នាក់ ដូច្នេះមិនទាន់បែកឈ្មោះថា គាត់ធ្វើសកម្មភាពអ្វីទេ ក៏គូសសង្កត់ថា អ្នកដឹកនាំដែលបែកឈ្មោះ ហើយមិនត្រូវនៅតទៅ

១០០ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៤៣

១០១ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៤៤



ទៀតទេ។ បើមិនដូច្នេះទេ នឹងនាំឲ្យប៉ះពាល់ដល់គេឯងផ្សេងទៀត។ ដូច្នេះលោកអៀង សារី ក៏យល់ស្របតាមដោយមិនអស់ចិត្តទេ។ នេះជាផ្លូវបត់ទី២ធំរបស់ចលនា។

### ៨- ឆ្នាំ១៩៦៣ ធ្លាក់ខ្លួនជាចំណាប់ខ្មាំងរបស់វៀតណាម ប៉ុន្តែដំណើរដោយឃឹតៗឆ្ពោះទៅរកឯករាជ្យនៅតែបន្ត

អ្នកនាំផ្លូវម្នាក់ដែលជាជនកុម្មុយនីស្តវៀតណាមខាងត្បូង បានជូនដំណើរលោក សាឡុតស ទៅដល់មូលដ្ឋានរបស់វៀតណាមមួយនៅចំបក់ជិតភូមិត្នោតខេត្តតៃនិញ។ មូលដ្ឋានរបស់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូងនៅជិតនេះ។ រហូតមកដល់ពេលនេះ លោក សាឡុតស មិនដឹងថា មូលដ្ឋានរបស់គេនៅជិតកម្ពុជាយ៉ាងនេះទេ។ ពន្លឺថ្ងៃមិនអាចចូលទៅក្នុងព្រៃដ៏ក្រាស់នេះបានទេ។ គេនៅទីនោះក្នុងមួយរយៈខ្លី មុខរបស់គេឡើងស្វាយពណ៌ដូចក្រមួន។

នៅក្នុងប៉ុន្មានអាទិត្យដំបូង គាត់មានគ្នាតែ៣នាក់ទេ គឺលោក សាឡុតស លោក អៀង សារី និង លោក សុន សេន។ ដូចនៅក្រៅ៩ឆ្នាំ មុននេះដែរ គេត្រូវហាមមិនឲ្យដើរចេញទៅណាមកណាទេ មិនឲ្យទាក់ទងភូមិខ្មែរនៅជិតនោះទេ។ យន្តហោះបានទម្លាក់គ្រាប់បែកនៅតាមព្រំដែនរួចហើយ ហើយបើមូលដ្ឋាននេះត្រូវបែក មិនមែនតែមូលដ្ឋានរបស់ខ្មែរប៉ុណ្ណោះទេដែលត្រូវប៉ះពាល់ ប៉ុន្តែធ្ងន់ជាងនេះទៀត គឺកន្លែងរបស់រណសិរ្សរំដោះជាតិវៀតណាមដែលនឹងត្រូវវាយប្រហារ។ ប៉ុន្តែ ស និងសហការីរបស់លោក មិនមែនជានិសិត្សឆោតល្ងង់ដូចកាលពីមុនទៀតទេ តែគេជាអ្នកដឹកនាំបក្សរបស់ជាតិមួយយ៉ាងហោចណាស់ ក៏ជាទ្រឹស្តីដែរ ដែលស្មើភាពជាមួយបក្សវៀតណាម។ នៅត្នោត គេទាំង៣នាក់ហាក់ដូចជាមនុស្សដាច់ដោយឡែក គេមានសិទ្ធិស្តាប់បានតែវិទ្យុ ហើយមួយអាទិត្យម្តង "វៀតកុងជាម្ចាស់ផ្ទះមកជួបគេ ដើម្បីជំរាបគេពីសភាពការណ៍ម្តង"។[១០២]

១០២ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៤៦

ប៉ុន្តែដោយការរាតត្បាតនៅភ្នំពេញចេះតែបង្កើនខ្លាំង គេក៏បានគ្នាកាន់តែច្រើនៗ កែវ មាស និងគ្រួសារដែលពួននៅខាងឧត្តរ ក៏មកដល់នៅពាក់កណ្តាលឆ្នាំៗ មន្ទីរនាំសារមួយក៏បានចាត់តាំងឡើងនៅក្នុងភូមិខ្មែរមួយចម្ងាយ៤ម៉ោងដោយថ្មើរជើងៗ ដូច្នេះ ស អាចសរសេរសារឡើងចុះជាមួយស្រុកខ្មែរ ដោយមិនឲ្យវៀតណាមដឹងទេៗ ដល់រវាងចុងឆ្នាំ មានគ្នាដល់ទៅ៦ ឬ៧នាក់ៗ ជីវិតរស់នៅ នៅទីនេះមិនធម្មតាទេ គឺដូចរស់នៅក្នុងផ្ទាំងចំហុយនំ មានរឿងអ្វីតែបន្តិច ក៏ផ្ទុះនាំឲ្យឈ្លោះគ្នាៗ ជាពិសេស កែវ មាស ត្អូញត្អែរថា ពួកមកពីប៉ារីសចេះតែជុំៗគ្នា ដើម្បីរៀបចំអ្វីមួយដោយមិនឲ្យគេដឹងៗ ការពិតគ្មាននរណាម្នាក់ដឹងថា ត្រូវធ្វើអ្វីផងនោះទេៗ

ដល់ដើមឆ្នាំ១៩៦៤ លោកសាឡុតស ក៏ពន្យល់ពួកវៀតកុងឲ្យខ្មែរអាចរៀបចំកន្លែងមួយរបស់ខ្លួន ដើម្បីជៀសវាងកុំឲ្យមានការស្មុគស្មាញខាងនយោបាយ ហើយដើម្បីខ្មែរអាចរៀបចំបដិវត្តន៍ជាជំហានៗដោយខ្លួនឯងៗ មូលដ្ឋាននេះហើយ ដែលគេហៅថាមន្ទីរ១០០ៗ មន្ទីរ១០០នេះនៅលើទឹកដីវៀតណាម នៅក្រោមការត្រួតត្រាយ៉ាងតឹងរឹងពីពួកវៀតកុងៗ ណីសារ៉ាន់ដែលមកដល់ពីភ្នំពេញនៅខែសីហា ហើយក្លាយទៅជាអ្នកកាន់កាប់ខាងកិច្ចការរដ្ឋបាលរបស់មូលដ្ឋានបានឃើញថា "មូលដ្ឋាននេះ អ្វីៗត្រូវពឹងពាក់ទាំងស្រុងលើវៀតណាម តាំងពីម្ហូបអាហារ សំភារៈផ្សេងៗ សន្តិសុខ គឺទាំងអស់....ៗ ដើម្បីដើរពីការិយាល័យមួយទៅការិយាល័យមួយទៀត យើងត្រូវការកងការពារម្នាក់របស់វៀតណាមជូនយើង.... គេជាម្ចាស់ផ្ទះហើយ យើងត្រូវតែគោរពធ្វើតាមគេ"ៗ

ប៉ុន្តែណីសារ៉ាន់ ក៏សម្គាល់ថា ខាងនយោបាយ និងមនោគមន៍វិជ្ជា "បន្តិចម្តងៗ....យើងចេះតែរីកចំរើនខាងគោលជំហរឯករាជ្យ"ៗ ការពិតចាប់ពីខែតុលាទៅ មានការប្រជុំនៃគណៈមជ្ឈឹមបើកទូលាយមួយនៅកណ្តាលព្រៃនៅក្នុងដីកម្ពុជាជិតព្រំដែនៗ គឺជាការប្រជុំលើកដំបូងហើយ ដែលខ្មែរទើបតែបានធ្វើៗ ការប្រជុំនេះបានធ្វើឡើងអស់ជាច្រើនអាទិត្យៗ មានឯកសារ



មួយរបស់បក្សដែលគេទើបរកឃើញនៅឆ្នាំ១៩៧៨ អះអាងថា "ការប្រជុំឆ្នាំ១៩៦៤....... ខិតខំរកវិធីដើម្បីទប់ទល់ ការរៀបចំអំពើក្បត់ដោយសម្ងាត់មួយរបស់សហរដ្ឋអាមេរិកៗ"[១០៣] សមាជិកម្នាក់របស់បក្សបានប្រាប់ស្ទីវហ៊ីឌ័រ នៅឆ្នាំ១៩៨០ប្រហាក់ប្រហែលគ្នានេះដែរៗ ក្នុងការរៀបចំសម្ងាត់នោះ សហរដ្ឋអាមេរិក គាំទ្រលោកលន់ នល់ ឬលោកសឺង ង៉ុកថាញ់ ប្រឆាំងនឹងស្តេចសីហនុៗ ក្នុងយថាហេតុ យ៉ាងនេះពួកខ្មែរក្រហមឃើញថា មិនអាចពឹងពាក់លើសម្ព័ន្ធភាពរបស់សម្តេច សីហនុ ជាមួយចិនឬវៀតណាមបានទេៗ គេត្រូវគិតគូររៀបចំការតស៊ូអាវុធរួមផ្សំនយោបាយៗ គេគូសបញ្ជាក់លើសារៈសំខាន់ជាអាយុជីវិត "នៃខ្លួនទីពឹងខ្លួន"ៗ

ហេតុដូចម្តេចបានជាលោក ប៉ុលពត និងសហការីរបស់គាត់មិនដល់១០នាក់ផង នៅដាច់ឆ្ងាយពីប្រទេសក្នុងព្រៃ ដែលពន្លឺថ្ងៃមិនអាចចូលបានផង ធ្លាក់ខ្លួនជាចំណាប់ខ្មាំងរបស់វៀតណាមដែលតាំងពីឆ្នាំ១៩៥៥មក រកតែវិធីដើម្បី "ចាប់គេឲ្យនៅស្ងៀម ហើយរស់នៅក្នុងជីវិតមួយប្លែកបំផុត ដូចក្នុងផ្ទាំងចំហុយនំ" ហេតុដូចម្តេចបានគេដឹងថា អាមេរិកកំពុងរៀបចំអំពើក្បត់ដោយសម្ងាត់មួយគាំទ្រលោក លន់ នល់ ឬលោកសឺង ង៉ុកថាញ់ ប្រឆាំងនឹងសម្តេច សីហនុ នោះ? គឺមកពីគេទាំងអស់គ្នា ពិសេស លោកសាឡុតស មានគោលការណ៍មួយ គឺព្រឹត្តិការណ៍អ្វីទាំងអស់តូចក្តី ធំក្តី មិនត្រូវទុកវាចោលទេ ត្រូវប្រមូលវាមកទាំងអស់ដើម្បីវិភាគៗ បញ្ជី៣៤នាក់ ក៏យកមកវិភាគ ការដែលគេត្រូវចេញពីភ្នំពេញឆ្នាំ១៩៦៣ ក៏យកមកវិភាគចំនួនមនុស្សដែលចូលមកក្នុងព្រៃនេះដែលកើនពីមួយខែទៅមួយខែ ពី៣នាក់ ដល់៦ ឬ៧នាក់ ក៏ត្រូវយកមកវិភាគៗ វិភាគទៅឃើញថា លោកលន់ នល់ បង្កើនការរាតត្បាតនៅក្នុងប្រទេស ដូច្នេះកម្លាំងដែលស្និទ្ធជាមួយអាមេរិកកាន់តែរីកធំធាត់ៗ ថ្ងៃណាមួយនឹងហ៊ុមព័ទ្ធសម្តេចនរោត្តម សីហនុៗ មេៗខ្មែរក្រហម ពិសេស

[១០៣] ដេវិត ឆាន់ឡែរ "បងធំទីមួយ" ទំព័រ៦៨, ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៤៦

លោកសាឡុតស អនុវត្តគោលការណ៍នេះលើគ្រប់បញ្ហា បញ្ហាផ្ទៃក្នុងក៏គេវិភាគតាមគោលការណ៍នេះ កម្មាភិបាលសំខាន់នីមួយៗ ក៏គេតាមដាន និងវិភាគតាមគោលការណ៍នេះ។ សេចក្ដីសម្រេចចិត្តនៃអង្គប្រជុំត្រូវសរសេរដោយដៃនៅលើស្តង់ស៊ីល ដែលគេរុំជុំវិញដបមួយដែលគេប្រើជារូឡូ ហើយគេពាសទឹកខ្មៅ ដែលបានមកដោយដុតស្បែកជើងកៅស៊ូចាស់ៗ ហើយគេរមាលលើក្រដាស់ៗ អត្ថបទដែលបានមកគេផ្ញើទៅពាសពេញប្រទេស។ លោក ទីកន ប្អូនលោក សុន សេន នៅចាំបានថា អ្នកនាំសារលាក់អត្ថបទទាំងនោះនៅក្នុងនំអន្សម ឬនៅក្នុងដប ដែលដាក់ប្រហុក ឬគេមូរអត្ថបទទាំងនោះឲ្យតូច ហើយញាត់ក្នុងបំពង់ឫស្សី ដើម្បីកុំឲ្យប៉ូលីសឃើញ។

បែន គៀរណាន់ បានសរសេរថា "មុនដាច់ឆ្នាំ១៩៦៤ ក្នុងពេលដែលលោកលន់ នល់ និងកម្លាំងខាងប៉ូលីសសម្ងាត់កំពុងតែបញ្ជោញកម្លាំងគេឲ្យទៅដេញចាប់អ្នកបដិវត្តន៍នៅជនបទ សេចក្ដីសម្រេចចិត្តនោះ ដែលគាត់ហៅថា "ពាក្យរបស់លោកប៉ុល ពត" បានទៅដល់អ្នកបដិវត្តន៍ល្មមចំពេលវេលា ដើម្បីពន្យល់ឲ្យគេរត់ចូលព្រៃត្រៀមរៀបចំការតស៊ូអាវុធរួមផ្សំនយោបាយ។ ទាក់ទងរឿងនេះ បែន គៀរណាន់ បានផ្ដល់ឧទាហរណ៍ដូចជាៈ ឧទាហរណ៍ទី១ ករណីលោក សូ ភឹម ដែល "ពាក្យរបស់ប៉ុល ពត" បានទៅដល់សាម៉ីខ្លួនទាន់ពេលវេលា, ឧទាហរណ៍ទី២ ករណីលោក កែវិន ដែល "ពាក្យ" នេះមិនបានទៅដល់សាម៉ីខ្លួន។ ករណីរបស់លោកសូ ភឹម "គាត់ហាក់ដូចជាបាត់ខ្លួនពីភូមិនៅចុងឆ្នាំ១៩៦៤ ដោយគ្មាននរណាមករកចាប់គាត់ ឬធ្វើបាបគាត់ទេ គាត់ទៅតាំងនៅជិតកូនអូរមួយនៅសំរោង នៅក្នុងឃុំដូនតី ខាងអាគ្នេយ៍ កំពង់ចាម។ នៅទីនោះ បើមានការអីគាត់រត់ទៅចូលក្នុងតំបន់របស់រណសិរ្សរំដោះជាតិខាងត្បូង នៅជាប់នឹងខេត្តតៃនិញ។ ឧទាហរណ៍មួយទៀត សញ្ញាដែលប្រាប់ឲ្យរត់មិនបានទៅដល់កែវិនទេ។ ក្រោយពីបានចេញពីគុកក្នុងឆ្នាំ១៩៥៧ គាត់ក៏បានទៅតាំងទីលំនៅ នៅភូមិកំណើតគាត់ នៅបារាយ ខេត្តកំពង់ធំបានកូន៦នាក់។ ហើយប្រកពមួយឲ្យដឹងថា គាត់



រស់នៅដោយសារលក់ស្រានិង ទិញមាន់លក់ ហើយធ្វើការងារនយោបាយផង។ ស្រាប់តែដល់ឆ្នាំ១៩៦៤ ប៉ូលីសទៅរកចាប់គាត់ នាំឲ្យគាត់ត្រូវរត់ចូលព្រៃចោលប្រពន្ធកូនដោយមិនបានត្រៀមស្មារតីជាមុន ព្រឹត្តិការណ៍នេះក៏នាំឲ្យគាត់ចងគំនុំយ៉ាងខ្លាំង ចំពោះរដ្ឋអំណាចរបស់សម្ដេចនរោត្តម សីហនុ ក៏ដូចចំពោះអ្នកណាទាំងអស់ ដែលទាក់ទិន្នដោយផ្ទាល់ក្ដី ដោយប្រយោលក្ដី និងការដែលធ្វើឲ្យគាត់ព្រាត់ប្រាស់ពីប្រពន្ធកូនយ៉ាងនេះ។ តាមលោកបែន គៀរណាន់បានសរសេរលោកថា ឈ្មោះកែពក គឺជាឈ្មោះថ្មីរបស់ កែវិន។ លោកបានដូរឈ្មោះនេះដើម្បីរំលឹកដល់កន្លែង និង ពេលដែលគាត់រត់ចូលព្រៃដំបូងនេះ។ កែពករហូតដល់ទៅប្រៀបផ្ទឹមសភាពការណ៍របស់គាត់ដែលគាត់ត្រូវរត់ទីណាត់ទីណែងទៅនឹងដំណើររបស់លោកសូភឹម ដែលលោកបានដឹងសភាពការណ៍មុន ហើយចាកចេញពីភូមិកំណើតរបស់គាត់បានដោយរៀបរយជាងគាត់ទៅទៀត នាំឲ្យគាត់កើតមានគំនិតប្រណាំងប្រជែងជាមួយលោកសូភឹមថែមទៀត។ ការប្រណាំងប្រជែងនេះបានបន្តរហូតមករហូតដល់ឆ្នាំ១៩៦៨ ដែលលោកសូភឹមសម្លាប់ខ្លួនដោយខ្លួនឯងទើបចប់។

អ្នកនិពន្ធ ក៏បានផ្ដល់នូវឧទាហរណ៍ផ្សេងទៀតអំពី "ពាក្យរបស់ប៉ុលពត" (គឺសេចក្ដីសម្រេចចិត្តរបស់គណៈកម្មាធិការមជ្ឈិមបើកទូលាយ) បានទៅដល់អ្នកបដិវត្តន៍ ចំពេលដែលប៉ូលីស ទាហានកំពុងរកចាប់គាត់ ដូចជា កុយធួន ភួង ឈូក, មូល សម្បត្តិ, (រស់ ញឹម) អតីតបញ្ជាការយោធានៃរណសិរ្សរួបរួមឥស្សរៈនៅភូមិភាគពាយ័ព្យ។[១០៤]

នៅខែមករា ១៩៦៥ គណៈកម្មាធិការមជ្ឈិមប្រជុំម្ដងទៀត ដើម្បីពិនិត្យសេចក្ដីសម្រេចចិត្តលើកមុនថែមទៀត។ សេចក្ដីសម្រេចចិត្តដែលបានកែដោយអង្គប្រជុំលើកទី២នេះ បានវាយប្រហារទៅលើគំនិតរបស់ គ្រូតផៃហ្ស៊ីអំពី ការឆ្លងកាត់ដោយសន្តិវិធី "ទៅសង្គមនិយម" ហើយបញ្ជាក់តួនាទីនៃ

---

[១០៤] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២១២-២១៥

"ហិង្សាបដិវត្តន៍ប្រឆាំងនឹងចក្រពត្តិ និងបរិវារវា"។[១០៥] បញ្ហាដែលអាចនាំឲ្យទំនាស់ជាមួយវៀតណាម ដូចជាបញ្ហាសម្តេច សីហនុ និង សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម ឈប់ទទួលដំបូន្មានពីវៀតណាមជាដើម -ឬមួយនិយាយដោយពាក្យពេចន៍ដែលប្រយ័ត្នប្រយែងបំផុត ឬមួយមិននិយាយនៅក្នុងអត្ថបទតែម្តង។

### ជ-ឆ្នាំ១៩៦៥ ការប៉ះទង្គិច ជាលើកទី១ជាមួយអ្នកដឹកនាំវៀតណាម

នៅខែមករា ១៩៦៥ អង្គប្រជុំនៃគណៈកម្មាធិការមជ្ឈិមដដែលនោះ ក៏សម្រេចឲ្យលោក សាឡុតស ដឹកនាំគណៈប្រតិភូបក្សខ្មែរទៅហាណូយ។ រហូតមកដល់ថ្ងៃនេះ ពួកកុម្មុយនីស្តខ្មែរទាក់ទងតែជាមួយការិយាល័យខាងត្បូងនៃបក្សពលករវៀតណាមទេ។ ឥឡូវនេះទិសដៅ គឺត្រូវទៅរៀបចំការទាក់ទងរវាងបក្ស និងបក្សឲ្យបានពេញលេញ ហើយទៅរកការស្រុះស្រួលគ្នាលើទិសជាយុទ្ធសាស្ត្រទូទៅមួយរបស់បក្សខ្មែរ តាមពន្លឺនៃការឈានឡើងជាប់ជានិច្ចនៃសង្គ្រាមនៅវៀតណាមខាងត្បូង។

គេត្រូវរង់ចាំដល់ដើមខែមេសា ដើម្បីចម្លើយយល់ស្របពីហាណូយមកដល់។ លោក សាឡុតស ក៏ចេញដំណើរទៅទិសឦសានកម្ពុជា ជាមួយកែវ មាស រួចគាត់ក៏ត្រូវចូលទៅផ្លូវលំហូជីមិញដែលពេលនោះ គ្មានអ្វីក្រៅពីដានអ្នកដឹកជញ្ជូន ដែលដើរកាត់ភ្នំរបស់លាវ តម្រង់ទៅផ្លូវភ្នំដែលវៀតណាមហៅថា ផ្លូវភ្នំទ្រៀងស៊ឺងនោះទេ។ ដំណើរត្រូវទាមទារពេលវេលាអស់២ខែកន្លះ។

ពេលទៅដល់លោកសាឡុតស ជួប ហូជីមិញ ដែលគាត់ត្រូវជួប២លើកទៀតនៅក្នុងពេលទស្សនកិច្ចរបស់គាត់។ ឡេ យន់ លេខាទូទៅនៃបក្សពលករវៀតណាម ធ្លាប់ជួបជាមួយពួកកុម្មុយនីស្តខ្មែរ រួចហើយកាលពេលដែលគាត់នៅទទួលខុសត្រូវការិយាល័យខាត្បូងក្នុងអំឡុងឆ្នាំ១៩៤០ និង

១០៥ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៥៦



១៩៥០។ នៅក្នុងរយៈ៥ខែនៃទស្សនកិច្ចរបស់គាត់ ស និង ឡេ យន់ ជួបគ្នា១២ដង។ ដល់ថ្ងៃក្រោយ ស នឹកឃើញពីការជួបគ្នាជាមួយ ឡេ យន់នេះថា "មិនមែនជាការរីករាយសប្បាយប៉ុន្មានទេ"[១០៦] ឈ្មោះកាយស៊ីម៉ី)។ ស ថា "ពាក្យក្រៅវៀតណាមថា ទទួលស្គាល់ឯករាជភាពរបស់បក្សខ្មែរ ប៉ុន្តែនៅក្នុងផ្លូវរបស់គេ គេមិនទទួលយើងខ្ញុំជាស្មើភាពទេ...យើងមានទស្សនៈខុសគ្នាច្រើនណាស់។ យើងមិនបានឈានដល់ទស្សនៈរួមមួយជាមួយគ្នាទេ"។

ហាណូយមិនចង់ឃើញឲ្យមានការបះបោរមួយនៅកម្ពុជាទេ។ ការគិតគូររបស់អ្នកដឹកនាំវៀតណាមទាំងអស់ប្រមូលផ្តុំទៅលើតែការ ដែលកងទ័ពជើងគោកអាមេរិកចូលទៅវៀតណាមខាងត្បូងប៉ុណ្ណោះ។ គេមិនចង់ឃើញឲ្យកើតមានរឿងនៅកន្លែងផ្សេងទៀតទេ។ ការសម្រេចរបស់សម្តេចនរោត្តម សីហនុ ផ្តាច់ការទាក់ទងទូតជាមួយសហរដ្ឋអាមេរិក មានន័យថា ទោះជាចង់ឬមិនចង់ក៏ដោយសម្តេចជាសម្ព័ន្ធមិត្តមួយរបស់វៀតណាមហើយ។ ហើយសំខាន់ជាងនេះទៅទៀត គឺប្រហែលជានៅខែមីនា ឬមេសា មុននេះសម្តេចទើបតែបានយល់ស្របឲ្យរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង តាំងជម្រក ជាស្ថិតស្ថេរនៅលើដីខាងខ្មែរនៃព្រំដែន។ ពីមុនលោកគ្រាន់តែធ្មេចព្រះនេត្រតែប៉ុណ្ណោះ នៅពេលដែលពួកវៀតកុងចូលមកក្នុងដីខ្មែរម្តងៗ។ ហើយការចរចាកំពុងតែដំណើរការ
ដើម្បីបានទទួលកិច្ចព្រមព្រៀងមួយលើការដឹក
ជញ្ជូនអាវុធតាមកប៉ាល់ពីចិន មកឲ្យរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងតាមកំពង់ផែព្រះសីហនុ ដើម្បីបំពេញការដឹកជញ្ជូនតាមខ្នងមនុស្ស តាមផ្លូវលំហូជីមិញដ៏លំបាក។

ឡេ យន់ បានខំអស់ពីលទ្ធភាពរបស់ខ្លួនដើម្បីពន្យល់ខ្មែរថា ការតស៊ូនយោបាយ វាមានតម្លៃខ្ពស់ណាស់ ហើយវាជា "ការរៀបចំខាងចាត់តាំង និង

១០៦ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៥៦ (អ្នកនិពន្ធយោងទៅតាមសេចក្តីសំភាសន៍របស់ប៉ុល ពត ជាមួយអ្នកកាសែតចិននៅឆ្នាំ១៩៨២)